ក

# មាតិកា

## I_ខុទ្ទកាល័យព្រះមហាក្សត្រ

### ព្រះរាជក្រឹត្យ


១០-១១-២០០៤ -ព្រះរាជក្រឹត្យ នស/រកត/១១០៤/០១២ ស្តីពីការតែងតាំង ឯកឧត្តម **ហោ សុខគង់** ជាឧបការីផ្ទាល់ប្រធានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា មានឋានៈស្មើ **អនុរដ្ឋលេខាធិការ** ២៦៦៦

១៦-១១-២០០៤ -ព្រះរាជក្រឹត្យ នស/រកត/១១០៤/០១៦ ស្តីពីការតែងតាំង ឯកឧត្តម **នាយ គីម** ជាទីប្រឹក្សារាជរដ្ឋាភិបាលកម្ពុជាមានឋានៈស្មើ **រដ្ឋមន្ត្រី** បន្ថែមលើមុខងារបច្ចុប្បន្ន ២៦៦៧

១៦-១១-២០០៤ -ព្រះរាជក្រឹត្យ នស/រកត/១១០៤/០១៧ ស្តីពីការតែងតាំង ឯកឧត្តម **ជា ចំរើន** ជាទីប្រឹក្សារាជរដ្ឋាភិបាលកម្ពុជា មានឋានៈស្មើ **រដ្ឋមន្ត្រី** ២៦៦៨

១៦-១១-២០០៤ -ព្រះរាជក្រឹត្យ នស/រកត/១១០៤/០១៨ ស្តីពីការតម្លើងឋានន្តរស័ក្តិថ្នាក់ **ឧត្តមសេនីយ៍ត្រី** ជូននាយនគរបាលជាតិជាន់ខ្ពស់ នៃអគ្គស្នងការដ្ឋាននគរបាលជាតិ ក្រសួងមហាផ្ទៃ ចំនួន ០២ រូប ២៦៦៩

១៦-១១-២០០៤ -ព្រះរាជក្រឹត្យ នស/រកត/១១០៤/០១៩ ស្តីពីការផ្តល់សញ្ជាតិខ្មែរ ដោយអាពាហ៍ពិពាហ៍ជូនលោក **រូស្កូនី អូលីវីយ៉េរ៉ូ** (RUSCONI Oliviero)សញ្ជាតិដើមអ៊ីតាលី កើតនៅ ឡេកកូ ប្រទេសអ៊ីតាលី ២៦៧០

២០-១១-២០០៤ -ព្រះរាជក្រឹត្យ នស/រកត/១១០៤/០២១ ស្តីពីការតែងតាំង ឯកឧត្តម **ម៉ោញ សំអាត** ជាទីប្រឹក្សាអមទីស្តីការគណៈរដ្ឋមន្ត្រី មានឋានៈស្មើអគ្គនាយក បន្ថែមលើមុខងារបច្ចុប្បន្ន ២៦៧១

២០-១១-២០០៤ -ព្រះរាជក្រឹត្យ នស/រកត/១១០៤/០២២ ស្តីពីការតែងតាំង ឯកឧត្តម **នី នរិន្ទ** ជាប្រធាននៃអាជ្ញាធរអគ្គិសនីកម្ពុជា មានឋានៈស្មើ **រដ្ឋលេខាធិការ** សំរាប់អាណត្តិទីពីរបន្តទៀត ២៦៧២

២២-១១-២០០៤ -ព្រះរាជក្រឹត្យ នស/រកត/១១០៤/០២៤ ស្តីពីការតែងតាំង ឯកឧត្តម **ផាន់ គិន** ជាទីប្រឹក្សាអមក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ មានឋានៈស្មើ អនុរដ្ឋលេខាធិការ ២៦៧៣


## II_រាជរដ្ឋាភិបាល

### ១_អនុក្រឹត្យ


១៧-១១-២០០៤ -អនុក្រឹត្យ លេខ ៧៦ អនក្រ.បក ស្តីពីការផ្ទេរភោគទានថវិកា ២៦៧៤

| | | |
|---|---|---|
| ១៨-១១-២០០៤ | -អនុក្រឹត្យ លេខ ៧៧ អនក្រ.បក ស្តីពីការរៀបចំសមាសភាព រចនាសម្ព័ន្ធតួនាទីភារកិច និងការប្រព្រឹត្តទៅរបស់ក្រុមប្រឹក្សាស្ថារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ | ២៦៧៦ |
| ១៨-១១-២០០៤ | -អនុក្រឹត្យ លេខ ៧៨ អនក្រ.បក ស្តីពីការបំពេញបន្ថែម និងកែសម្រួលនាយកដ្ឋានមួយចំនួន នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ | ២៦៨៤ |
| ១៨-១១-២០០៤ | -អនុក្រឹត្យ លេខ ៧៩ អនក្រ.បក ស្តីពីការប្រើប្រាស់គណនីឯកជនភាវូបនីយកម្មសហគ្រាសសាធារណៈ | ២៦៩២ |
| ២២-១១-២០០៤ | -អនុក្រឹត្យ លេខ ៨០ អនក្រ.បក ស្តីពីការផ្ទេរឥណទានថវិកា | ២៦៩៤ |
| ១៦-១១-២០៤ | -អនុក្រឹត្យ លេខ ៦០៤ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ | ២៦៩៦ |
| ១៦-១១-២០០៤ | -អនុក្រឹត្យ លេខ ៦០៥ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ | ២៦៩៦ |
| ១៧-១១-២០០៤ | -អនុក្រឹត្យ លេខ ៦០៦ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ | ២៦៩៨ |
| ២២-១១-២០០៤ | -អនុក្រឹត្យ លេខ ៦០៧ អនក្រ.តត ស្តីពីការកែសម្រួលមាត្រា ១ នៃអនុក្រឹត្យលេខ ៣៣ អនក្រ.បក ចុះថ្ងៃទី ០៣ ខែសីហា ឆ្នាំ ២០០៤ ស្តីពីការផ្ទេរក្របខ័ណ្ឌមន្ត្រីរាជការស៊ីវិល រវាងក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា អតីតក្រសួងកិច្ចការនារី និងអតីតយុទ្ធជន ក្រសួងអប់រំយុវជន និងកីឡា និងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | ២៦៩៩ |
| ២៣-១១-២០០៤ | -អនុក្រឹត្យ លេខ ៦០៨ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ | ២៧០១ |
| ២៣-១១-២០០៤ | -អនុក្រឹត្យ លេខ ៦០៩ អនក្រ.តត ស្តីពីការដាក់មន្ត្រីរាជការឱ្យឈប់បំរើការងារពីក្របខ័ណ្ឌរដ្ឋ | ២៧០២ |
| ២៣-១១-២០០៤ | -អនុក្រឹត្យ លេខ ៦១០ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ | ២៧០៣ |
| ២៣-១១-២០០៤ | -អនុក្រឹត្យ លេខ ៦១១ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ | ២៧០១ |


## ២_សេចក្តីសំរេច


| | | |
|---|---|---|
| ១៦-១១-២០០៤ | -សេចក្តីសំរេចលេខ ៧០ សសរ ស្តីពីការកំណត់បទដ្ឋាននៃការ ប្រើប្រាស់ដីធ្លី នៅតំបន់ ១ និងតំបន់ ២ ក្នុងតំបន់រមណីយដ្ឋានសៀមរាប-អង្គរ | ២៧០៥ |
| ១៨-១១-២០០៤ | -សេចក្តីសំរេចលេខ ៧១ សសរ ស្តីពីការបង្កើតគណៈកម្មការអន្តរក្រសួងដើម្បីរៀបចំខួប ១០ ឆ្នាំ នៃការរស់ឡើងវិញវិស័យខ្លែងខ្មែរ ថ្ងៃទី ១១-១២-១៣ ខែធ្នូ ឆ្នាំ ២០០៤ | ២៧០៨ |
| ១៩-១១-២០០៤ | -សេចក្តីសំរេចលេខ ៧២ សសរ ស្តីពីការបង្កើតក្រុមការងារបច្ចេកទេសចំរុះ រាជរដ្ឋាភិបាល-ប្រទេសម្ចាស់ជំនួយ លើវិស័យមីន | ២៧១០ |

គ


២៣-១១-២០០៤ -សេចក្តីសំរេចលេខ ៧៣ សសរ ស្តីពីការបង្កើតគណៈកម្មការ ដើម្បីធ្វើការសម្របសម្រួលជាមួយធនាគារឥណទានស៊ុីស ក្នុងការផ្តល់ស្ថិតិ និងព័ត៌មានផ្សេងៗជូនភ្នាក់ងារ កម្រិតថ្នាក់ ដើម្បីធ្វើការវាយតម្លៃលើបរិស្ថាន វិនិយោគ និងលើស្ថានភាពជារួមនៃប្រទេសកម្ពុជា ២៧១២


## III.ការងារបណ្តាក្រសួង

### ១.ទីស្តីការរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ


១៨-១១-២០០៤ -ប្រកាសលេខ ៨៦៩ សហវ.ប្រក ស្តីពីការកែសំរួលសមាសភាពគណៈកម្មាធិការដឹកនាំការអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ២៧១៤


### ២.ទីស្តីការរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម


១៩-១១-២០០៤ -ប្រកាសលេខ ២៣៣ MOC/M 2004 ស្តីពីស្ថានភាពរោងចក្រកាត់ដេរ LUEN THAI GARMENT (CAMBODIA) CO.,LTD. ២៧១៩

# ព្រះរាជក្រឹត្យ

នស/រកត/១១០៤/០១២

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់បទបញ្ជាផ្ទៃក្នុងរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែកក្កដា ឆ្នាំ ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- យោងតាមសេចក្តីក្រាបបង្គំទូលស្នើសុំរបស់សម្តេចក្រុមព្រះ **នរោត្តម រណឫទ្ធិ** ប្រធានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា លេខ ២៩៦ រស ចុះថ្ងៃទី ១៨ ខែសីហា ឆ្នាំ ២០០៤
- យោងលើភាពចាំបាច់នៃការងារ

## ព្រះរាជក្រឹត្យ

**មាត្រា១ .-** តែងតាំងឯកឧត្តម **ឃោច សុខគង់** ជាឧបការីផ្ទាល់ប្រធានរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា មានឋានៈស្មើ **អនុរដ្ឋលេខាធិការ** ។

**មាត្រា២ .-** ប្រធានរដ្ឋសភា និងនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឱ្យបានសំរេច តាមព្រះរាជក្រឹត្យនេះ ។

**មាត្រា៣ .-** ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

*៣រល.០៤១១.០១២*

*ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែវិច្ឆិកា ឆ្នាំ២០០៤*

ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០០៤
អគ្គលេខាធិការរាជរដ្ឋាភិបាល

ណាឌី តាន់

# ព្រះរាជក្រឹត្យ

នស/រកត/១១០៤/០១៦

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរជនា សម្ពោហនាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា
សិរីវិបុលា ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស / រកម / ០៧០៤ / ០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស / រកត / ០៧០៤ / ១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់ សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ .-** តែងតាំង ឯកឧត្តម ឆាយ គីម ជាទីប្រឹក្សារាជរដ្ឋាភិបាលកម្ពុជា មានឋានៈស្មើ **រដ្ឋមន្ត្រី** បន្ថែមលើមុខងារបច្ចុប្បន្ន ។

**មាត្រា ២ .-** សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣ .-** ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

នរោត្តម សីហមុនី

៣៧.០៤១១.០១៦

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ២០០៤

លេខៈ ២៩៤ ចល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ, ថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០០៤
អគ្គលេខាធិការរាជរដ្ឋាភិបាល

ឈាវ តាន់

# ព្រះរាជក្រឹត្យ

នស/រកត/១១០៤/០១៧

## យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា
សិរីវិបុលា ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១.-** តែងតាំងឯកឧត្តម **ជា ចំរើន** ជាទីប្រឹក្សារាជរដ្ឋាភិបាលកម្ពុជា មានឋានៈស្មើ **រដ្ឋមន្ត្រី** ។

**មាត្រា ២.-** សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣.-** ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

៣រល.០៤១១.០១៧

នរោត្តម សីហមុនី

*ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ១៦ ខែវិច្ឆិកា ឆ្នាំ ២០០៤*

លេខៈ ២៤៣ចល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ,ថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០០៤
អគ្គលេខាធិការរាជរដ្ឋាភិបាល

ឈាវី តាន់

# ព្រះរាជក្រឹត្យ

នស/រកត/១១០៤/០១៤

យើង

ព្រះករុណាព្រះបាទសម្ដេចព្រះបរមនាថ នរោត្តម សីហមុនី
សមានគ្មមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សម្ពហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា
សិរីវិបុលា ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រម លេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្ដីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្ដីពីលក្ខន្តិកៈដោយឡែក នៃគ្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានទ្រង់យល់សេចក្ដីក្រាបបង្គំទូលថ្វាយរបស់សម្ដេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១.-** តម្លើងឋានន្តរស័ក្តិថ្នាក់ **ឧត្តមសេនីយ៍ត្រី** ជូននាយនគរបាលជាតិជាន់ខ្ពស់ នៃអគ្គស្នងការដ្ឋាននគរបាលជាតិ ក្រសួងមហាផ្ទៃ ដូចមានរាយនាមខាងក្រោម :

១-វរៈសេនីយ៍ឯក **ម៉ែន ឈុនលី** អត្តលេខ ០១០៧
២-វរៈសេនីយ៍ឯក **ឈឹម សារឧន** អត្តលេខ ០៤៤០

**មាត្រា ២.-** សម្ដេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣.-** ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

[illegible]

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០០៤

អគ្គលេខាធិការរាជរដ្ឋាភិបាល

[illegible]

*តារ.០៤១១.០១៤*

*ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ១៦ ខែវិច្ឆិកា ឆ្នាំ ២០០៤*

# ព្រះរាជក្រឹត្យ

នស/រកត/១១០៤/០១៩

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្ត្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រម លេខ នស/រកម/១០៩៦/៣០ ចុះថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

ត្រាស់បង្គាប់

**មាត្រា ១.-**

ផ្តល់សញ្ជាតិខ្មែរ ដោយអាពាហ៍ពិពាហ៍ជូនលោក រូស្កូនី អូលីវីយេរ៉ូ ( RUSCONI Oliviero ) សញ្ជាតិដើមអ៊ីតាលី កើតថ្ងៃទី ២៥ ខែ មិថុនា ឆ្នាំ ១៩៥៣ នៅឡេកកូ ប្រទេសអ៊ីតាលី ។

**មាត្រា ២.-**

សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តអោយបានសំរេច នូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣.-**

ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះ តទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

នរោត្តម សីហមុនី

៣រល.០៤១១.០១៩

*ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ២០០៤*

បានឃើញ ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ២០០៤
អគ្គលេខាធិការរាជរដ្ឋាភិបាល

ស្វាន់ គាន់

# ព្រះរាជក្រឹត្យ

នស/រកត/១១០៤/០២១

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** តែងតាំងឯកឧត្តម **ម៉ៅញូ សំអាត** ជាទីប្រឹក្សាអមទីស្តីការគណៈរដ្ឋមន្ត្រី មានឋានៈស្មើអគ្គនាយក បន្ថែមលើមុខងារបច្ចុប្បន្ន ។

**មាត្រា ២ :** សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តអោយបានសំរេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣ :** ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

៣៧.០៤១១.០២១

*ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញ, ថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ២០០៤*

លេខៈ ៦២៥៨ ចល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០០៤
អគ្គលេខាធិការរាជរដ្ឋាភិបាល
ឈាឌី គាន់

# ព្រះរាជក្រឹត្យ

នស/រកត/១១០៤/០២២

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរាជរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០២០១/០៣ ចុះថ្ងៃទី ០២ ខែ កុម្ភៈ ឆ្នាំ ២០០១ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១** : តែងតាំងឯកឧត្តម **ធី នរិទ្ធ** ជាប្រធាននៃអាជ្ញាធរអគ្គិសនីកម្ពុជា មានឋានៈស្មើ **រដ្ឋលេខាធិការ** សំរាប់អាណត្តិទីពីរបន្តទៀត ។

**មាត្រា ២** : សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តអោយបានសំរេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣** : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ៕

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

នរោត្តម សីហមុនី

ចរល.០៤១១.០៧៦

*ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញ, ថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ២០០៤*

លេខ ... ចល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី២៣ខែវិច្ឆិកា ឆ្នាំ២០០៤
អគ្គលេខាធិការរាជរដ្ឋាភិបាល

ឈាវ ឌី តាន់

# ព្រះរាជក្រឹត្យ

នស/រកត/១១០៤/០២៤

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរជ្ជបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២ /នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/២០ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** ត្រូវបានតែងតាំង ឯកឧត្តម **ផាន់ តិន** ជាទីប្រឹក្សាអមក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ មានឋានៈស្មើអនុរដ្ឋលេខាធិការ ។

**មាត្រា ២ :** សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តឱ្យបានសំរេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣ :** ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

*៣រល-០៤១១-០២៤*

*ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី២២ ខែ វិច្ឆិកា ឆ្នាំ ២០០៤*

លេខ: ៧៩៧ ចរ
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី២៣ ខែ វិច្ឆិកា ឆ្នាំ២០០៤
អគ្គលេខាធិការរាជរដ្ឋាភិបាល

[illegible] គាន់

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា

លេខ ៖ ៧៧០ អនក្រ.បក

## អនុក្រឹត្យ

## ស្តីពីការផ្ទេរឥណទានថវិកា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ , ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃ ព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ , ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ , ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក , ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ ០១/នស/៩៣ ,ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ដែលប្រកាសអោយប្រើច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ ដែលត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម លេខ ១០/នស/៩៤ , ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤ និង ត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០០ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២៩៩/១៥ , ចុះថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ១៩៩៩ និងត្រូវបានកែប្រែដោយច្បាប់ស្តីពីវិសោធនកម្មមាត្រា ២៦ នៃច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២០២/០២០ ,ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០២
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០២/០២១ , ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០២ ដែលប្រកាសអោយប្រើច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០៣
- បានឃើញអនុក្រឹត្យលេខ ១៣១ អនក្រ.បក ,ចុះថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ ២០០២ ស្តីពីការបែងចែកចំណាយថវិកាទូទៅរបស់រដ្ឋតាមជំពូកនៃច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ២០០៣
- បានឃើញអនុក្រឹត្យលេខ ៨៣ អនក្រ.បក , ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០៣ ស្តីពីការអនុវត្តន៍ថវិកាមួយភាគដប់ពីរជាបណ្តោះអាសន្ន សំរាប់ការគ្រប់គ្រងឆ្នាំ ២០០៤
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

## សំរេច

**មាត្រា១:** ត្រូវបានអនុញ្ញាតអោយផ្ទេរឥណទានថវិកា ចំនួន ៦.៣០០ លានរៀល ( ប្រាំមួយពាន់បីរយលានរៀលគត់ ) ពីជំពូក ១៣ ៖ សកម្មភាពនៃកម្មវិធី ( ដែលមានផ្នែកអប់រំ ចំនួន ១.០១០ លានរៀល ( មួយពាន់ដប់លានរៀលគត់ ) ផ្នែកឧត្តមសិក្សា ចំនួន ៣.៣០០ លានរៀល ( បីពាន់បីរយលានរៀលគត់ ) និងផ្នែកយុវជន និងកីឡា ចំនួន ១.៩៩០ លានរៀល ( មួយពាន់ប្រាំបួនរយកៅសិបលានរៀលគត់ ) មកជំពូក ១១ ៖ ចំណាយទំនើបកម្មការិយាល័យ សំភារៈ និងការជួសជុលតូច ) របស់ក្រសួងអប់រំយុវជន និងកីឡា ផ្នែកអប់រំ សំរាប់ការគ្រប់គ្រងឆ្នាំ ២០០៤ ស្តីពីការបែងចែកចំណាយឥណទានថវិកាមួយភាគដប់ពីរបណ្តោះអាសន្ន ។

**មាត្រា២:** ការបែងចែកឥណទានថវិកាចំណាយផ្ទៃក្នុងជំពូកទាំងនេះ តាមប្រការ កថាខណ្ឌ និង វាក្យខណ្ឌ ត្រូវធ្វើឡើងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ សំរាប់បង្គ្រប់លើការចំណាយប្រចាំឆ្នាំ ២០០៤ ។

**មាត្រា៣:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យ នេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ១៩ ខែ វិច្ឆិកា ឆ្នាំ ២០០៤

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- កាលប្បវត្តិ - ឯកសារ

បានយកសេចក្តីជំរាបជូន

សម្តេចនាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា

គាត ឈន់

ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ១៦៧ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការរៀបចំសមាសភាព រចនាសម្ព័ន្ធ តួនាទី ភារកិច្ច និងការប្រព្រឹត្តទៅ របស់ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញអនុក្រឹត្យលេខ ៩៩ អនក្រ-បក ចុះថ្ងៃទី ២៧ ខែ កញ្ញា ឆ្នាំ ២០០១ ស្តីពីការរៀបចំ សមាសភាព រចនាសម្ព័ន្ធ តួនាទីភារកិច្ច និងការប្រព្រឹត្តទៅ របស់ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្មនិងជនបទ
- យោងតាមការងារចាំបាច់របស់រាជរដ្ឋាភិបាល

### សម្រេច

### ជំពូកទី ១
### បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

អនុក្រឹត្យនេះកំណត់ពីការរៀបចំ សមាសភាព រចនាសម្ព័ន្ធ តួនាទី ភារកិច្ច និង ការប្រព្រឹត្តទៅរបស់ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ សរសេរកាត់ជាអក្សរខ្មែរថា កកជ និងជាអក្សរឡាតាំងថា CARD ។

# ជំពូកទី ២
# សមាសភាព និង រចនាសម្ព័ន្ធរបស់ កកជ

**មាត្រា ២.-**

សមាសភាពក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និង ជនបទ មានដូចតទៅ :

| | |
|---|---|
| - នាយករដ្ឋមន្ត្រី | ប្រធាន |
| - ឥស្សរជនមួយរូបមានឋានៈស្មើរដ្ឋមន្ត្រី | អនុប្រធាន |
| - អនុប្រធានទី ១ គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ | សមាជិក |
| - រដ្ឋមន្ត្រី ឬ តំណាងទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| - រដ្ឋមន្ត្រី ឬ តំណាងក្រសួងមហាផ្ទៃ | សមាជិក |
| - រដ្ឋមន្ត្រី ឬ តំណាងក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ | សមាជិក |
| - រដ្ឋមន្ត្រី ឬ តំណាងក្រសួងអភិវឌ្ឍន៍ជនបទ | សមាជិក |
| - រដ្ឋមន្ត្រី ឬ តំណាងក្រសួងសុខាភិបាល | សមាជិក |
| - រដ្ឋមន្ត្រី ឬ តំណាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ | សមាជិក |
| - រដ្ឋមន្ត្រី ឬ តំណាងក្រសួងធនធានទឹក និង ឧតុនិយម | សមាជិក |
| - រដ្ឋមន្ត្រី ឬ តំណាងក្រសួងបរិស្ថាន | សមាជិក |
| - រដ្ឋមន្ត្រី ឬ តំណាងក្រសួងពាណិជ្ជកម្ម | សមាជិក |
| - រដ្ឋមន្ត្រី ឬ តំណាងក្រសួងផែនការ | សមាជិក |
| - រដ្ឋមន្ត្រី ឬ តំណាងក្រសួងសាធារណការ និង ដឹកជញ្ជូន | សមាជិក |
| - រដ្ឋមន្ត្រី ឬ តំណាងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ | សមាជិក |
| - រដ្ឋមន្ត្រី ឬ តំណាងក្រសួងកិច្ចការនារី | សមាជិក |
| - អគ្គទេសាភិបាលធនាគារជាតិ ឬ តំណាង | សមាជិក |
| - ប្រធានធនាគារអភិវឌ្ឍន៍ជនបទ ឬ តំណាង | សមាជិក |
| - ប្រធានឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ ឬ តំណាង | សមាជិក |
| - ប្រធានមូលនិធិកាត់បន្ថយភាពក្រីក្រ ឬ តំណាង | សមាជិក |
| - អគ្គលេខាធិការ ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និង ជនបទ | សមាជិក |
| - អគ្គនាយកមូលនិធិសង្គមនៃព្រះរាជាណាចក្រកម្ពុជា | សមាជិក |
| - មេបញ្ជាការ-បញ្ជាការដ្ឋានវិស្វកម្មនៃអគ្គបញ្ជាការដ្ឋានកងយោធពលខេមរភូមិន្ទ | សមាជិក |

**មាត្រា ៣.-**

ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និង ជនបទ មានគណៈកម្មាធិការប្រតិបត្តិមួយសំរាប់ដឹកនាំការងារប្រចាំថ្ងៃ ។ គណៈកម្មាធិការប្រតិបត្តិនៃ កកជ មានសមាសភាពរួម ដូចតទៅ :

ប្រធាន កកជ

អនុប្រធាន កកជ

អគ្គលេខាធិការ កកជ

អគ្គលេខាធិការរង កកជ ។

**មាត្រា ៤.-**

បង្កើតអគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និង ជនបទ ដែលស្ថិតនៅក្រោមការគ្រប់គ្រងផ្ទាល់របស់អគ្គលេខាធិការមួយរូប និង មានអគ្គលេខាធិការរងមួយចំនួន ជាជំនួយការ តាមការ ចាំបាច់ ។

អគ្គលេខាធិការដ្ឋាននៃ កកជ មាននាយកដ្ឋានជំនាញចំនួន៧ ដូចខាងក្រោម :

- នាយកដ្ឋាន រដ្ឋបាល
- នាយកដ្ឋាន ផ្គត់ផ្គង់ និង ហិរញ្ញវត្ថុ
- នាយកដ្ឋាន កសិកម្ម រួមមាន: ផលិតកម្មស្បៀង ការចិញ្ចឹមសត្វ ជលផល កៅស៊ូ និង ព្រៃឈើ
- នាយកដ្ឋាន អភិវឌ្ឍន៍ជនបទ
- នាយកដ្ឋានធនធានទឹក
- នាយកដ្ឋាន ផែនការ និង សហប្រតិបត្តិការអន្តរជាតិ
- នាយកដ្ឋានស្ថិតិ-ទិន្នន័យសន្តិសុខស្បៀងនិងអាហារូបត្ថម្ភ ។

**មាត្រា ៥.-**

អគ្គលេខាធិការមានឋានៈស្មើ រដ្ឋលេខាធិការ ។ អគ្គលេខាធិការរងមានឋានៈស្មើ អនុរដ្ឋលេខាធិការ ។

**មាត្រា ៦.-**

នាយកដ្ឋានទីមួយៗ ដឹកនាំដោយប្រធានមួយរូប ហើយមានអនុប្រធាន និង ការិយាល័យចំណុះមួយចំនួន តាមការចាំបាច់ ។

## ជំពូកទី ៣

## តួនាទី និង ភារកិច្ចរបស់ កកជ

**មាត្រា ៧.-**

ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទមានតួនាទីជាគណៈបញ្ជាការឯកភាពមួយជំនួយការអោយរាជរដ្ឋាភិបាល ក្នុងវិស័យស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និង ជនបទ ដោយសហការគ្នាយ៉ាងជិតស្និទ្ធ និង ធ្វើការសម្របសម្រួលការងារជាមួយបណ្តាក្រសួង ស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធ ជាពិសេសជាមួយ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ក្រសួង កសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ក្រសួងធនធានទឹក និង ឧតុនិយម ក្រសួងអភិវឌ្ឍន៍ជនបទ ក្រសួង

សាធារណៈការ និង ដឹកជញ្ជូន ដើម្បីអនុវត្តអោយស៊ីសង្វាក់ប្រទាក់ក្រឡាគ្នា និង មានប្រសិទ្ធភាព ព្រមទាំងមានសិទ្ធិសម្រេចអំពីមធ្យោបាយ សម្ភារៈ ទុន និង ការងារផ្សេងៗទៀតដែលជួយអោយសម្រេចរាល់ភារកិច្ចដែលមានចែងក្នុងមាត្រា ៨ ។

**មាត្រា ៨.-**

ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និង ជនបទ មានភារកិច្ចដូចខាងក្រោម :

- ទទួលបន្ទុកចាត់ចែងតាមដាន និងផ្តល់យោបល់លើការអនុវត្តនូវកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាល ដូចជា កម្មវិធីជាតិ នីតិសម្បទា អភិវឌ្ឍន៍កម្ពុជា ការស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និង ជនបទ សំដៅប្រែក្លាយវិស័យកសិកម្មដែលមានទម្លាប់ធ្វើ សម្រាប់ផ្គត់ផ្គង់ខ្លួនឯង អោយទៅជាការផលិតសម្រាប់នាំចេញ ព្រមទាំងកាត់បន្ថយជាជំហានៗនូវ គម្លាតរវាង ជនបទ និង ទីក្រុង
- កំណត់កត្តាគន្លឹះទាំងឡាយដែលបំរើអោយការស្តារ និង អភិវឌ្ឍន៍វិស័យកសិកម្ម និង ជនបទ
- កំណត់អាទិភាព និង កម្មវិធីនយោបាយក្នុងការស្តារ និង អភិវឌ្ឍន៍វិស័យកសិកម្ម និង ជនបទ អោយសមស្របតាមគោលនយោបាយនៃរាជរដ្ឋាភិបាល
- ត្រួតពិនិត្យ និង តាមដានរាល់ការអនុវត្តគំរោងនានាទាក់ទងនឹងវិស័យសន្តិសុខស្បៀង អាហារូបត្ថម្ភ និង អភិវឌ្ឍន៍ជនបទ របស់ក្រសួង ស្ថាប័នពាក់ព័ន្ធ ដើម្បីបង្កើនប្រសិទ្ធភាពការងារ និងធ្វើរបាយការណ៍ ជូនរាជរដ្ឋាភិបាល
- ចលនា និង សម្របសម្រួលអោយមានការចូលរួមយ៉ាងកុះករពីប្រជារាស្ត្រ ជាពិសេសក្រុមហ៊ុនឯកជន សហគមន៍ជនបទ អង្គការអន្តរជាតិ អង្គការក្រៅរដ្ឋាភិបាល ជាមួយក្រសួង ស្ថាប័ន ខេត្ត ក្រុង ដើម្បីបង្កនូវភាពងាយស្រួល និង ភាពសហការគ្នាល្អក្នុងការស្តារ និង អភិវឌ្ឍន៍វិស័យកសិកម្ម និង ជនបទ ដើម្បីធានាសន្តិសុខស្បៀងនិងអាហារូបត្ថម្ភ សំដៅកាត់បន្ថយ ភាពក្រីក្រនៅជនបទ
- ពិនិត្យផ្តល់យោបល់លើសំណើដែលបានស្នើសុំពីក្រសួង ស្ថាប័ន និងអង្គការដែលធ្វើការពាក់ព័ន្ធដល់ការស្តារ និង អភិវឌ្ឍន៍វិស័យកសិកម្មនិងជនបទ ហើយរាយការណ៍ និងសុំយោបល់ពីរាជរដ្ឋាភិបាលលើបញ្ហាសំខាន់ៗ ដែលស្ថិតក្នុងសមត្ថកិច្ចរបស់រាជរដ្ឋាភិបាល ។

## ជំពូកទី ៤
## ដំណើរការប្រព្រឹត្តទៅរបស់ គកជ

**មាត្រា ៩.-**

ប្រធាន គកជ មានតួនាទី និង ភារកិច្ចដូចតទៅ :

- ទទួលខុសត្រូវលើការងាររបស់ គកជ
- ធ្វើជាអធិបតីក្នុងអង្គប្រជុំរបស់ គកជ និង អង្គប្រជុំរបស់គណៈកម្មាធិការប្រតិបត្តិ គកជ

- ដឹកនាំពិភាក្សា និង បូកសរុបមតិសម្រេចរបស់អង្គប្រជុំពេញអង្គ កកជ និង អង្គប្រជុំរបស់គណៈកម្មាធិការប្រតិបត្តិរបស់ កកជ
- កោះប្រជុំសាមញ្ញ ឬ ក្នុងករណីចាំបាច់ប្រជុំវិសាមញ្ញនៃអង្គប្រជុំ កកជ និង អង្គប្រជុំរបស់គណៈកម្មាធិការប្រតិបត្តិ កកជ ។

**មាត្រា ១០.-**

អនុប្រធាន កកជ មានតួនាទី និង ភារកិច្ចដូចតទៅ :

- ទទួលខុសត្រូវជាទូទៅលើការងារ កកជ ក្នុងករណីប្រធានអវត្តមាន
- ទទួលខុសត្រូវក្នុងការដឹកនាំ និង គ្រប់គ្រងការងារប្រចាំថ្ងៃរបស់ កកជ
- ធ្វើជាអធិបតីនៃអង្គប្រជុំ កកជ និង អង្គប្រជុំគណៈកម្មាធិការប្រតិបត្តិ កកជ និង ចុះហត្ថលេខាលើកំណត់ហេតុ និង លើសេចក្តីជូនដំណឹងនៃអង្គប្រជុំរបស់ កកជ
- ទទួលបន្ទុកការងារសម្របសម្រួលអន្តរក្រសួងរវាង កកជ ជាមួយក្រសួង ស្ថាប័ន នៃរាជរដ្ឋាភិបាល
- ទទួលបន្ទុកទំនាក់ទំនងជាមួយភាគីបរទេស ដែលពាក់ពន្ធ័ក្នុងការងារស្តារអភិវឌ្ឍន៍វិស័យ កសិកម្ម និង ជនបទ ។

**មាត្រា ១១.-**

អគ្គលេខាធិការ កកជ មានតួនាទី និង ភារកិច្ចដូចតទៅ :

- ទទួលបន្ទុកចាត់ចែងគ្រប់គ្រងការងាររបស់អគ្គលេខាធិការដ្ឋាននៃ កកជ
- រៀបចំកម្មវិធីរបស់ កកជ និង រៀបចំរបៀបវារៈ និង សំណុំឯកសារផ្សេងៗសំរាប់អង្គប្រជុំរបស់ កកជ និង អង្គប្រជុំរបស់គណៈកម្មាធិការប្រតិបត្តិ កកជ
- រៀបចំកំណត់ហេតុ សេចក្តីជូនដំណឹងអង្គប្រជុំនៃ កកជ និង អង្គប្រជុំគណៈកម្មាធិការប្រតិបត្តិ កកជ ដើម្បីដាក់ជូនអនុប្រធាន កកជ ចុះហត្ថលេខា
- រៀបចំរបាយការណ៍ កកជ ប្រចាំត្រីមាស ប្រចាំឆមាស ឬ ប្រចាំឆ្នាំ
- រៀបចំប្រកាសពត៌មានរបស់ កកជ
- ចូលរួមប្រជុំ កកជ និង អង្គប្រជុំគណៈកម្មាធិការប្រតិបត្តិ កកជ
- បំពេញការងារផ្សេងៗទៀតដែលប្រធាន និង អនុប្រធាន កកជ ប្រគល់អោយ ។

**មាត្រា ១២.-**

អគ្គលេខាធិការរងនីមួយៗ បំពេញកិច្ចការ ភារកិច្ច តាមការប្រគល់ជូនរបស់អគ្គលេខាធិការ ។

**មាត្រា ១៣.-**

សមាជិក កកជ មានតួនាទី និង ភារកិច្ចដូចតទៅ :

- ចូលរួមប្រជុំសាមញ្ញ និង វិសាមញ្ញនៃអង្គប្រជុំរបស់ កកជ ដើម្បីពិនិត្យសម្រេចរាល់សំណើរបស់ស្ថាប័នដែលពាក់ព័ន្ធដល់ការស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និង ជនបទ
- សមាជិកដែលជាប្រធានស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធដល់ការស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និង ជនបទ មានភារកិច្ចលើកកម្មវិធីនយោបាយ របាយការណ៍ វិធានការ សំណើផ្សេងៗមក កកជ ដើម្បីពិនិត្យសំរេច
- ពិនិត្យសំរេចលើរបាយការណ៍របស់ កកជ ប្រចាំត្រីមាស ប្រចាំឆមាស ឬ ប្រចាំឆ្នាំ ។

**មាត្រា ១៤.-**

កកជ ត្រូវកោះប្រជុំសាមញ្ញយ៉ាងតិច បីខែម្តង ។

**មាត្រា ១៥.-**

គណៈកម្មាធិការប្រតិបត្តិនៃ កកជ ត្រូវកោះប្រជុំសាមញ្ញពីរសប្តាហ៍ម្តង ។

**មាត្រា ១៦.-**

កកជ មានសិទ្ធិអញ្ជើញប្រធានស្ថាប័ន ឬ តំណាងស្ថាប័ន ឬ ទីប្រឹក្សាតាមការចាំបាច់ ដើម្បីចូលរួមប្រជុំ កកជ ឬ ប្រជុំគណៈកម្មាធិការប្រតិបត្តិ កកជ ។

**មាត្រា ១៧.-**

អនុប្រធាន កកជ អាចចូលរួមប្រជុំពេញអង្គគណៈរដ្ឋមន្ត្រីតាមការអញ្ជើញរបស់ទីស្តីការគណៈរដ្ឋមន្ត្រី។

**មាត្រា ១៨.-**

រាល់សកម្មភាពរដ្ឋបាល ថវិកាចំណាយរបស់ កកជ ប្រាក់បៀវត្ស និង ប្រាក់បំណាច់ផ្សេងៗរបស់មន្ត្រីរាជការជាបន្ទុករបស់ទីស្តីការគណៈរដ្ឋមន្ត្រី។

**មាត្រា ១៩.-**

ការប្រព្រឹត្តិទៅនៃអង្គប្រជុំរបស់ កកជ អង្គប្រជុំរបស់គណៈកម្មាធិការប្រតិបត្តិ ការរៀបចំ និង ការប្រព្រឹត្តិទៅ នៃអគ្គលេខាធិការដ្ឋាន កកជ ត្រូវកំណត់ក្នុងបទបញ្ជាផ្ទៃក្នុងរបស់ កកជ ។

**មាត្រា ២០.-**

កកជ ប្រើត្រាដោយឡែករបស់ខ្លួន ។

# ជំពូកទី៥

# អវសានប្បញ្ញត្តិ

**មាត្រា ២១.-**

ការរៀបចំសមាសភាព រចនាសម្ព័ន្ធ តួនាទី ភារកិច្ច និង ការប្រព្រឹត្តទៅរបស់ក្រុមប្រឹក្សាស្តារ-អភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ ដែលកំណត់ដោយអនុក្រឹត្យលេខ៩៩ អនក្រ.បក ចុះថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០០១ ស្តីពីការរៀបចំសមាសភាព រចនាសម្ព័ន្ធ តួនាទី ភារកិច្ច និង ការប្រព្រឹត្តទៅរបស់ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ ត្រូវកែសំរួលស្របតាមខ្លឹមសារនៃអនុក្រឹត្យនេះ ។

**មាត្រា ២២.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ២៣.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងសមាជិកក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ ដូចមានចែងក្នុងមាត្រា ២ ត្រូវអនុវត្តខ្លឹមសារនៃ អនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*រាជធានីភ្នំពេញ, ថ្ងៃទី [illegible] ឆ្នាំ២០០៤*

**ហ៊ុន សែន**

បានយកសេចក្តីជំរាបជូន

សម្តេចនាយករដ្ឋមន្ត្រី សូមហត្ថលេខា

**ទេសរដ្ឋមន្ត្រី**

**សាច សេងហួរ**

***កន្លែងទទួល*:**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ដូចមាត្រា ២៣
- រាជកិច្ច
- កាលប្បវត្តិ-ឯកសារ

ឧបសម្ព័ន្ធនៃអនុក្រឹត្យលេខ ៧៧/អនក្រ.បក ស្តីពីការរៀបចំសមាសភាព រចនាសម្ព័ន្ធ តួនាទី ភារកិច្ច និងការប្រព្រឹត្តិទៅរបស់ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និង ជនបទ ចុះថ្ងៃទី ១៨ វិច្ឆិកា ២០០៤

# រចនាសម្ព័ន្ធក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ "ថ្មី"



**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ៧៥៨ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការបំពេញបន្ថែម និង កែសម្រួលនាយកដ្ឋានមួយចំនួន នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

## រាជរដ្ឋាភិបាល

- បានឃើញ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០១ នស ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ ដែលត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុ សម្រាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ ១០/នស/៩៤ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤ និងត្រូវបានកែប្រែដោយច្បាប់ស្តីពីវិសោធនកម្មមាត្រា ២៦ នៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ២០០០ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខនស/រកម/១២៩៩/១៥ ចុះថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ ១៩៩៩ និង ត្រូវបានកែប្រែដោយច្បាប់ស្តីពីវិសោធនកម្មមាត្រា ២៦ នៃច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១២០២/០២០ ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០២
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ២០ អនក្រ. បក ចុះថ្ងៃទី ៣០ ខែ មេសា ឆ្នាំ១៩៩៦ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅរបស់ក្រសួង និង រដ្ឋលេខាធិការដ្ឋាន
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- យោងតាមការចាំបាច់របស់ក្រសួង

## សម្រេច

### ជំពូកទី១

### បទប្បញ្ញត្តិទូទៅ

**មាត្រា១ . -**

អនុក្រឹត្យនេះ មានគោលបំណងបំពេញបន្ថែម និង កែសម្រួលនាយកដ្ឋានមួយចំនួន ទៅតាមខ្លឹមសារ និង រចនាសម្ព័ន្ធដែលមានចែងក្នុងអនុក្រឹត្យលេខ ០៤ អនក្រ. បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

**មាត្រា២ . -**

ត្រូវបានបំពេញបន្ថែមនាយកដ្ឋានចំនួន ០២ ដូចខាងក្រោម ដែលស្ថិតចំណុះក្រសួង សេដ្ឋកិច្ច និង ហិរញ្ញវត្ថុៈ

- នាយកដ្ឋានសវនកម្មផ្ទៃក្នុង
- នាយកដ្ឋានចំណូលមិនមែនសារពើពន្ធ

**មាត្រា៣ . -**

ត្រូវបានកែសម្រួលនាយកដ្ឋានថវិកានីយកម្ម និង ហិរញ្ញកិច្ច ដែលមានចែងក្នុងជំពូកទី ៩ នៃអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ដោយបែងចែកចេញទៅជាពីរនាយកដ្ឋានវិញ គឺនាយកដ្ឋានថវិកា និងនាយកដ្ឋានហិរញ្ញកិច្ច ។

**មាត្រា៤ . -**

ត្រូវបានកែសម្រួលឈ្មោះនាយកដ្ឋានវិភាគ និង ព្យាករណ៍សេដ្ឋកិច្ច ដែលមានចែងក្នុងជំពូកទី ១២ នៃអនុក្រឹត្យលេខ ០៤ អនក្រ. បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ទៅជានាយកដ្ឋានគោលនយោបាយសេដ្ឋកិច្ច និង ហិរញ្ញវត្ថុសាធារណៈ ។

### ជំពូកទី២

### អំពីរចនាសម្ព័ន្ធគ្រប់គ្រង

**មាត្រា៥ . -**

នាយកដ្ឋានសវនកម្មផ្ទៃក្នុង នាយកដ្ឋានចំណូលមិនមែនសារពើពន្ធ នាយកដ្ឋានថវិកា នាយកដ្ឋានហិរញ្ញកិច្ច និង នាយកដ្ឋានគោលនយោបាយសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

សាធារណៈ ដឹកនាំ និងគ្រប់គ្រង ដោយប្រធាននាយកដ្ឋានមួយរូប និងមានអនុប្រធាននាយកដ្ឋានមួយចំនួន ជាជំនួយការ ។

នាយកដ្ឋានសវនកម្មផ្ទៃក្នុង នាយកដ្ឋានចំណូលមិនមែនសារពើពន្ធ នាយកដ្ឋានថវិកា នាយកដ្ឋានហិរញ្ញកិច្ច និង នាយកដ្ឋានគោលនយោបាយសេដ្ឋកិច្ច និង ហិរញ្ញវត្ថុសាធារណៈ មានការិយាល័យចំណុះមួយចំនួន តាមការចាំបាច់ ។

ការរៀបចំ និង ការប្រព្រឹត្តិទៅរបស់ការិយាល័យចំណុះនៃនាយកដ្ឋានទាំងអស់នេះ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

## ជំពូកទី៣

## អំពីភារកិច្ច

**មាត្រា៦.-**

នាយកដ្ឋានសវនកម្មផ្ទៃក្នុងរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ មានភារកិច្ចធ្វើជាសេនាធិការឱ្យក្រសួងលើការងារៈ

- ពិនិត្យលើមុខងារ សកម្មភាព កម្មវិធី និង ប្រតិបត្តិការនានារបស់ស្ថាប័ន និង អង្គភាពក្រោមឱវាទក្រសួង ក្នុងការិយបរិច្ឆេទសមស្របដើម្បីកំណត់ការអនុវត្តន៍ឱ្យបានសមស្របនូវការរៀបចំផែនការ ការចេញបទបញ្ជា ការចាត់តាំងការងារ និង ការត្រួតពិនិត្យដោយផ្អែកតាមគោលនយោបាយ ការណែនាំរបស់ថ្នាក់ដឹកនាំ និង នីតិវិធីជាធរមាន និងស្របតាមគោលដៅរបស់ក្រសួង
- កំណត់ភាពសមស្រប និងប្រសិទ្ធភាពប្រព័ន្ធគ្រប់គ្រងផ្ទៃក្នុងផ្នែកគណនេយ្យ រដ្ឋបាល និង កិច្ចប្រតិបត្តិការរបស់ស្ថាប័ន និង អង្គភាពនៅក្រោមឱវាទក្រសួង
- ពិនិត្យលើភាពដែលអាចជឿជាក់បាន ការិយបរិច្ឆេទ និង ភាពពេញលេញនៃពត៌មាន និង ទិន្នន័យ និងលើវិធីសាស្ត្រនៃការរៀបចំរបាយការណ៍ពីពត៌មាន និងទិន្នន័យទាំងនេះ
- ពិនិត្យលើប្រព័ន្ធដែលបានបង្កើតរួច ដើម្បីធានាភាពត្រឹមត្រូវតាមគោលនយោបាយ ផែនការ នីតិវិធី ច្បាប់ និង បទប្បញ្ញត្តិនានា ហើយលើកសំណើកែតម្រូវ និង កែលំអប្រសិនបើមានកំហុស
- ពិនិត្យលើមធ្យោបាយ ក្នុងការថែរក្សាសម្បត្តិរដ្ឋ
- វាយតំលៃភាពសន្សំសំចៃ និងប្រសិទ្ធភាពសេដ្ឋកិច្ចនៃការប្រើប្រាស់ធនធានរដ្ឋ ហើយលើកសំណើដោះស្រាយ និង កែលំអការអនុវត្តន៍ប្រតិបត្តិការ

- ធ្វើសវនកម្មលើកិច្ចប្រតិបត្តិការចំណូល ចំណាយថវិការដ្ឋ ដើម្បីបញ្ជាក់ពីភាពត្រឹមត្រូវនៃរបាយការណ៍ហិរញ្ញវត្ថុរបស់មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុខេត្ត- ក្រុង និងបណ្ដាអង្គភាពផ្សេងៗនៅក្រោមឱវាទក្រសួង
- សម្របសម្រួលការងារសវនកម្មផ្ទៃក្នុងជាមួយអគ្គាធិការដ្ឋាន និង អាជ្ញាធរសវនកម្មជាតិ ដើម្បីធានាដំណើរការការងារឱ្យបានគ្រប់គ្រាន់ និងសមស្របជាពិសេសកាត់បន្ថយការងារស្ទួនគ្នា
- ធ្វើរបាយការណ៍ជូនរដ្ឋមន្ត្រីក្រសួង អំពីការប្រព្រឹត្តិទៅរបស់អង្គភាព ដែលបានធ្វើសវនកម្មរួចហើយ ។ ទន្ទឹមនឹងនោះ ត្រូវធ្វើរបាយការណ៍អំពីសកម្មភាពការងាររបស់ខ្លួនប្រចាំត្រីមាស និង ប្រចាំឆ្នាំ ដើម្បីធ្វើជូនរដ្ឋមន្ត្រីពិនិត្យ និង ផ្ដល់ការណែនាំ
- ផ្ដល់អនុសាសន៍ ដើម្បីកែលំអការអនុវត្តន៍ឱ្យមានប្រសិទ្ធភាពខ្ពស់ និង តាមដានការអនុវត្តន៍កែលំអរបស់នាយកដ្ឋាន មន្ទីរខេត្ត- ក្រុង និង បណ្ដាអង្គភាពក្រោមឱវាទក្រសួង
- រៀបចំផែនការសវនកម្មផ្ទៃក្នុងប្រចាំឆ្នាំ ដើម្បីដាក់ជូនរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ពិនិត្យ និង សម្រេច ។

**មាត្រា៧ .** -

នាយកដ្ឋានចំណូលមិនមែនសារពើពន្ធ មានភារកិច្ចធ្វើជាសេនាធិការ ឱ្យក្រសួងលើការងារ ÷

- រៀបចំគោលនយោបាយ និង យុទ្ធសាស្ត្រ ក្នុងការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ
- រៀបចំលិខិតបទដ្ឋានានា ស្ដីពីការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ
- បូកសរុបចំណូល និង បំណុលមិនមែនសារពើពន្ធ យ៉ាងទៀងទាត់ ជារៀងរាល់ខែ
- ប្រមូលផ្ដុំពត៌មានស្ដីពីចំណូលមិនមែនសារពើពន្ធ
- គ្រប់គ្រងការងារប្រមូលចំណូលប្រៃសណីយ៍ និង ទូរគមនាគមន៍ អាករនៃស្ថានទូត លិខិតឆ្លងដែន ទិដ្ឋាការវាយនភ័ណ្ឌ ទេសចរណ៍ អាកាសចរណ៍ស៊ីវិល និងចំណូលមិនមែនសារពើពន្ធផ្សេងៗទៀត ក្រៅពីទ្រព្យរដ្ឋ និង ឧស្សាហកម្មហិរញ្ញវត្ថុ
- គ្រប់គ្រងការងារ និងចំណូលស្ថិតក្រោមការគ្រប់គ្រងរបស់អាជ្ញាធរប្រេងកាត អាជ្ញាធរអប្សរា អាជ្ញាធរអគ្គិសនី អាជ្ញាធរអាកាសចរស៊ីវិល និងអាជ្ញាធរផ្សេងៗទៀតពាក់ព័ន្ធនឹងចំណូលរបស់រដ្ឋ
- ដោះស្រាយទំនាស់វិវាទតាមផ្លូវច្បាប់ និង តុលាការ ពាក់ព័ន្ធនឹងការគ្រប់គ្រងចំណូល និង បំណុលមិនមែនសារពើពន្ធ ដោយសហការជាមួយនាយកដ្ឋាននីតិកម្ម
- រៀបចំ ជំរុញអនុវត្តការតឹងទារបំណុលមិនមែនសារពើពន្ធ ក្នុងគ្រប់បណ្ដានៃសមត្ថកិច្ចរបស់ខ្លួនឱ្យបានប្រសិទ្ធភាពខ្ពស់ និង ដោយឡែករៀបចំវិធានការតឹងទារចំពោះបំណុល

មិនមែនសារពើពន្ធ សំរាប់ដាក់ជូនរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុពិនិត្យ និង សម្រេច និង ណែនាំឱ្យនាយកដ្ឋានពាក់ព័ន្ធអនុវត្ត

- ស្រាវជ្រាវរកប្រភពចំណូលមិនមែនសារពើពន្ធផ្សេងៗទៀត
- ចូលរួមរៀបចំគម្រោងថវិកាប្រចាំឆ្នាំ ដើម្បីបញ្ចូលប្រភពចំណូលថវិកា ទៅក្នុងសេចក្តីព្រាងច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំនីមួយៗ ។

**មាត្រា៨.-**

នាយកដ្ឋានថវិកា មានភារកិច្ចធ្វើជាសេនាធិការឱ្យក្រសួង លើការងាររៀបចំ និង អនុវត្តថវិកា តាមមុខសញ្ញាដូចខាងក្រោមៈ

***ក. ការកសាងសេចក្តីព្រាងច្បាប់ និង បទបញ្ញាហិរញ្ញវត្ថុសាធារណៈ***

- រៀបចំកម្មវិធីចំណូល ចំណាយសាធារណៈរបស់ក្រសួង-ស្ថាប័នរដ្ឋបាលកណ្តាល និង មន្ទីរជំនាញ នៅតាមខេត្ត-ក្រុង
- ដឹកនាំកិច្ចដំណើរការបច្ចេកទេស ដើម្បីរៀបចំសេចក្តីព្រាងច្បាប់ហិរញ្ញវត្ថុ សម្រាប់ការគ្រប់គ្រងឆ្នាំនីមួយៗ
- ចូលរួមរៀបចំគម្រោងក្របខ័ណ្ឌការងារចំណាយរយៈពេលមធ្យម
- ស្រាវជ្រាវ និង បង្កើតបទដ្ឋានចំណូល-ចំណាយ ដើម្បីធ្វើជាមូលដ្ឋានក្នុងការកសាងសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំនីមួយៗ និង បទបញ្ញានានា
- រៀបចំកញ្ចប់តួលេខចំណូល-ចំណាយដំបូងរបស់មន្ទីរជំនាញនៅខេត្ត-ក្រុង និងថវិកាខេត្ត-ក្រុង
- ណែនាំដល់បណ្តាក្រសួង-ស្ថាប័ន និងមន្ទីរជំនាញនៅតាមខេត្ត-ក្រុងក្នុងការអនុវត្តន៍ និង ការទូទាត់ថវិកាប្រចាំឆ្នាំ ។

***ខ. ការចាត់ចែងអនុវត្តច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ ច្បាប់ស្តីពីហិរញ្ញវត្ថុ សម្រាប់គ្រប់គ្រងឆ្នាំនីមួយៗ***

- រៀបចំសន្ទស្សន៍ចំណូល-ចំណាយថវិកាឱ្យបណ្តាក្រសួង-ស្ថាប័ន និង មន្ទីរជំនាញនៅតាមខេត្ត-ក្រុង ដើម្បីអនុវត្ត
- កត់ត្រាចុះបញ្ជីគណនេយ្យថវិកា ដើម្បីឆ្លុះបញ្ចាំងនូវសភាពការណ៍អនុវត្តថវិកាប្រចាំថ្ងៃ សប្តាហ៍ ខែ ត្រីមាស ឆមាស និង ឆ្នាំ
- ជម្រុញការរៀបចំរបាយការណ៍ប្រញាប់ របាយការណ៍គណនេយ្យ និង ចូលរួមកសាងតារាងប្រតិបត្តិការហិរញ្ញវត្ថុប្រចាំខែ
- ណែនាំអំពីមុខជំនាញបច្ចេកទេសហិរញ្ញវត្ថុ ថវិកាដល់បណ្តាអង្គភាពជំនាញ ទៅតាមបណ្តាក្រសួង-ស្ថាប័ន និងមន្ទីរជំនាញខេត្ត-ក្រុង

- តាមដានការអនុវត្តន៍ចំណូល- ចំណាយថវិការបស់ក្រសួង- ស្ថាប័ន និងមន្ទីរជំនាញខេត្ត- ក្រុង
- ពិនិត្យ និង ផ្តល់មតិជូនក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ លើសំណើសុំចបេឥណទាន សំណើសុំបន្ថែមឥណទាន និង សំណើសុំបុរេប្រទានឥណទានថវិកា ក្នុងករណីមានតម្រូវការចាំបាច់ជាបន្ទាន់របស់ក្រសួង- ស្ថាប័នរដ្ឋបាលកណ្តាល និង មន្ទីរជំនាញនៅតាមខេត្ត- ក្រុង ។

*គ- ការកសាងសេចក្តីព្រាងច្បាប់សម្រាប់ទូទាត់ថវិកាប្រចាំឆ្នាំ*

- រៀបចំសេចក្តីព្រាងច្បាប់ទូទាត់ថវិការបស់ក្រសួង- ស្ថាប័នរដ្ឋបាលកណ្តាល និងមន្ទីរជំនាញនៅខេត្ត- ក្រុង
- បូកសរុបរាល់សភាពការណ៍អនុវត្តថវិកា ប៉ាន់ស្មានការអនុវត្តន៍ ដើម្បីវិភាគ និង វាយតម្លៃអំពីសភាពការណ៍សេដ្ឋកិច្ច និង ហិរញ្ញវត្ថុ នាឆ្នាំខាងមុខ ។

**មាត្រា៩. -**

នាយកដ្ឋានហិរញ្ញកិច្ចមានភារកិច្ចធ្វើជាសេនាធិការ ឱ្យក្រសួងលើការងារ ÷

- អនុវត្តអនុក្រឹត្យលេខ ៨១ អនក្រ. បក ស្តីពីការបង្កើតការត្រួតពិនិត្យហិរញ្ញវត្ថុ លើចំណាយថវិការដ្ឋនៅតាមក្រសួងខេត្ត- ក្រុង ក្រុងស្វយ័តរាជធានីភ្នំពេញ និង អង្គភាពសាធារណៈរដ្ឋបាល និង អនុក្រឹត្យលេខ ៨២ អនក្រ. បក ស្តីពីបទបញ្ជាទូទៅនៃគណនេយ្យសាធារណៈ ចុះថ្ងៃទី ១៦ ខែវិច្ឆិកា ឆ្នាំ ១៩៩៥ ឱ្យបានត្រឹមត្រូវ
- គ្រប់គ្រងសកម្មភាពសម្របសម្រួល និង តាមដានការអនុវត្តន៍របស់អភិបាលហិរញ្ញវត្ថុ
- កសាងជារៀងរាល់ខែនូវកិច្ចសន្យាចំណាយ ដើម្បីផ្ទៀងផ្ទាត់ជាមួយគណនេយ្យរដ្ឋបាលរបស់អាណាប័ក និង ជាមួយគណនេយ្យចំណូល- ចំណាយ ដែលធ្វើឡើងដោយផ្នែកនានារបស់ធនាគារជាតិ
- កសាងកម្មវិធីត្រួតពិនិត្យជាមុន ចំពោះអភិបាលហិរញ្ញវត្ថុអំពីលក្ខខណ្ឌនៃការអនុវត្តន៍ប្រសិទ្ធភាពចំណាយ ចំណូល ព្រមទាំងស្នើឡើងនូវវិធានការកែតម្រូវចាំបាច់ និងកសាងកម្មវិធីត្រួតពិនិត្យតាមក្រោយ ដោយសហការជាមួយនាយកដ្ឋានពាក់ព័ន្ធនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- ត្រួតពិនិត្យ និង ផ្តល់ទិដ្ឋាការនៃការសន្យាចំណាយ
- ផ្តល់ទិដ្ឋាការលើអណត្តិបើកប្រាក់
- ផ្តល់យោបល់បច្ចេកទេសដល់អាណាប័កក្នុងការគ្រប់គ្រងហិរញ្ញវត្ថុ
- ចូលរួមក្នុងការរៀបចំថវិកា និង ច្បាប់ហិរញ្ញវត្ថុ
- ចូលរួមជាសមាជិក ក្នុងគណៈកម្មាធិការលទ្ធកម្មសាធារណៈ ។

មាត្រា១០.-

នាយកដ្ឋានគោលនយោបាយសេដ្ឋកិច្ច និង ហិរញ្ញវត្ថុសាធារណៈ មានភារកិច្ចធ្វើជាសេនាធិការឱ្យក្រសួងលើការងារ ÷

- រៀបចំ និងតាមដាន ការអនុវត្តន៍គោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាធារណៈសម្រាប់រយៈពេលខ្លី រយៈពេលមធ្យម និង រយៈពេលវែង

- ប្រមូលផ្តុំ និង ធ្វើសំយោគទិន្នន័យចាំបាច់នានា ដើម្បីធ្វើការវិភាគ និង ព្យាករណ៍អំពីស្ថានភាពសេដ្ឋកិច្ច និង ហិរញ្ញវត្ថុជាតិ និង អន្តរជាតិ ហើយផ្អែកលើមូលដ្ឋាននេះ តាមដាន និង វាយតម្លៃអំពីការវិវត្តន៍នៃសកម្មភាពសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ក្នុងប្រទេស និង រៀបចំក្របខ័ណ្ឌម៉ាក្រូសេដ្ឋកិច្ច សម្រាប់ការប្រើប្រាស់របស់ក្រសួង

- រៀបចំក្របខ័ណ្ឌម៉ាក្រូសេដ្ឋកិច្ច សម្រាប់ការរៀបចំថវិកាប្រចាំឆ្នាំ

- ទទួលបន្ទុករៀបចំ និង វិភាគតារាងប្រតិបត្តិការហិរញ្ញវត្ថុសាធារណៈ

- តាមដាន និងវិភាគការអនុវត្តន៍ និងការប្រព្រឹត្តិទៅនៃហិរញ្ញវត្ថុសាធារណៈ និង កម្មវិធីចំណាយសាធារណៈ ហើយផ្អែកលើមូលដ្ឋាននេះ លើកយោបល់ និង ស្នើវិធានការជូនថ្នាក់ដឹកនាំក្រសួង ដើម្បីកែលំអការងារគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈឱ្យមានប្រសិទ្ធភាព និង មានតុល្យភាព

- ទទួលបន្ទុកសម្របសម្រួល និង តាមដានការអនុវត្តន៍កម្មវិធីកែតម្រូវរចនាសម្ព័ន្ធជាពិសេស ក្នុងក្របខ័ណ្ឌសហប្រតិបត្តិការខាងផ្នែកកែទម្រង់រចនាសម្ព័ន្ធសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ជាមួយនឹងស្ថាប័នហិរញ្ញវត្ថុអន្តរជាតិនានា ដូចជា មូលនិធិរូបិយវត្ថុអន្តរជាតិ និង ធនាគារពិភពលោក ជាដើម

- ទទួលបន្ទុកផ្សព្វផ្សាយអំពីសកម្មភាពសេដ្ឋកិច្ច និង ទិន្នន័យនានា ដែលរៀបចំដោយក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

- ទទួលបន្ទុកសម្របសម្រួល និង តាមដានការអនុវត្តន៍យុទ្ធសាស្ត្រជាតិកាត់បន្ថយភាពក្រីក្រ

- ចូលរួមរៀបចំគម្រោងថវិកាប្រចាំឆ្នាំ ដើម្បីបញ្ចូលទៅក្នុងសេចក្តីព្រាងច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំនីមួយៗ ។

## ជំពូក ទី ៤

## អវសានប្បញ្ញត្តិ

មាត្រា១១.-

មាត្រា ១១ នៃជំពូកទី ៩ ស្តីពីនាយកដ្ឋានថវិកានីយកម្ម និង ហិរញ្ញកិច្ច និង មាត្រា ១៤ នៃជំពូកទី ១២ ស្តីពីនាយកដ្ឋានវិភាគ និង ព្យាករណ៍សេដ្ឋកិច្ចនៃអនុក្រឹត្យលេខ ០៤

អនុក្រ. បកចុះថ្ងៃទី ២០ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃក្រសួង សេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និងបទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា១២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រី និង រដ្ឋលេខាធិការគ្រប់ក្រសួងស្ថាប័ន ដែលពាក់ព័ន្ធត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ឱ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ វិច្ឆិកា ឆ្នាំ ២០០៤

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

បានជំរាបជូន

សម្តេចនាយករដ្ឋមន្ត្រី

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

**គាត ឈន់**

***ចំលងជូន:***

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *ខុទ្ទកាល័យនាយករដ្ឋមន្ត្រី*
- *ទីស្តីការគណៈរដ្ឋមន្ត្រី*
- *គ្រប់ក្រសួង ស្ថាប័នកណ្តាល*
- *គ្រប់សាលាខេត្ត ក្រុង និង រាជធានីភ្នំពេញ*
- *ដូចមាត្រា ១២*
- *ឯកសារ កាលប្បវត្តិ*

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៧១៩ អនក្រ.បក

*អនុក្រឹត្យ*

**ស្តីពី**

**ការប្រើប្រាស់គណនី**

**ឯកជនភាវូបនីយកម្មសហគ្រាសសាធារណៈ**

៙✧៙

**រាជរដ្ឋាភិបាលកម្ពុជា**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសអោយប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានាដំណើរការជាប្រក្រតី នៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំង រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ ០១/នស/៩៣ ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ១៩៩៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ ដែលត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ១៩៩៥ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ ១០/នស/៩៤ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៩៤ និងត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ២០០០ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១២៩៩/១៥ ចុះថ្ងៃទី ២៥ ខែធ្នូ ឆ្នាំ១៩៩៩ និង ត្រូវបានកែប្រែដោយច្បាប់ស្តីពីវិសោធនកម្មមាត្រា ២៦ នៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១២០២/០២០ ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០២
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០២/០២១ ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ២០០៣
- បានឃើញអនុក្រឹត្យលេខ ៣៨ អនក្រ ចុះថ្ងៃទី១៩ ខែមេសា ឆ្នាំ១៩៩៥ ស្តីពីបែបបទនៃឯកជនភាវូបនីយកម្មសហគ្រាសសាធារណៈ
- បានឃើញអនុក្រឹត្យលេខ៦០ អនក្រ.បក ចុះថ្ងៃទី៣១ ខែកក្កដា ឆ្នាំ១៩៩៥ ស្តីពីការគ្រប់គ្រងលទ្ធកម្មសាធារណៈ
- បានឃើញប្រកាសរបស់រាជរដ្ឋាភិបាលចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ១៩៩៤ ស្តីពីឯកជនភាវូបនីយកម្មសហគ្រាសសាធារណៈ
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

## សំរេច

<u>មាត្រា</u> ១ : អនុញ្ញាតឱ្យក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ប្រើប្រាស់គណនី " ឯកជនភាវូបនីយកម្មសហគ្រាសសាធារណៈ " ដែលត្រូវបានបង្កើតឡើងតាមមាត្រា ៨៣ នៃច្បាប់ហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ១៩៩៥ ដើម្បីបង់ភាគហ៊ុនសំរាប់ចូលរួមជាភាគីជាមួយវិភាគទានរបស់ក្រុមហ៊ុនឯកជន តាមរូបភាពរដ្ឋ ៦០ ក្រុមហ៊ុនឯកជន ៤០% ក្នុងការស្ថាបនាផ្សារទំនើបនៅស្ទឹងមានជ័យរាជធានីភ្នំពេញ ដែលមានទឹកប្រាក់សរុបចំនួន ១.៣០៨.៣០០ដុល្លារអាមេរិក ។ ចំពោះទឹកប្រាក់ដែលត្រូវចំណាយពិតប្រាកដ និងកំណត់ច្បាស់លាស់ ក្រោយពីធ្វើបែបបទលទ្ធកម្មសាធារណៈរួច ។

<u>មាត្រា</u> ២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អភិបាលរាជធានីភ្នំពេញ រដ្ឋមន្ត្រី រដ្ឋលេខាធិការ ក្រសួងស្ថាប័នពាក់ព័ន្ធ មានភារកិច្ចអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០០៤

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

<u>កន្លែងទទួល</u>:

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋាន ព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋាន រដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ២
- កាលប្បវត្តិ-ឯកសារ

បានយកសេចក្តីជំរាបជូន
សម្តេចនាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា

**ទេសរដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា
លេខ :...៩០...អនក្រ.បក

### អនុក្រឹត្យ
### ស្តីពីការផ្ទេរឥណទានថវិកា

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ , ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃ ព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ , ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ , ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក , ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ ០១/នស/៩៣ ,ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ដែលប្រកាសអោយប្រើច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ ដែលត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម លេខ ១០/នស/៩៤ , ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤ និង ត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រង ឆ្នាំ ២០០០ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២៩៩/១៥ , ចុះថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ១៩៩៩ និងត្រូវបានកែប្រែដោយច្បាប់ស្តីពីវិសោធនកម្មមាត្រា ២៦ នៃច្បាប់ស្តីអំពីប្រពន្ធ័ហិរញ្ញវត្ថុ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២០២/០២០ ,ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០២
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០២/០២១ , ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០២ ដែលប្រកាសអោយប្រើច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០៣
- បានឃើញអនុក្រឹត្យលេខ ១៣១ អនក្រ.បក ,ចុះថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ ២០០២ ស្តីពីការបែងចែកចំណាយថវិកាទូទៅរបស់រដ្ឋតាមជំពូកនៃច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ២០០៣
- បានឃើញអនុក្រឹត្យលេខ ៨៣ អនក្រ.បក , ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០៣ ស្តីពីការអនុវត្តន៍ថវិកាមួយភាគដប់ពីរជាបណ្តោះអាសន្ន សំរាប់ការគ្រប់គ្រងឆ្នាំ ២០០៤
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

## សំរេច

**មាត្រា១:** ត្រូវបានអនុញ្ញាតអោយផ្ទេរឥណទានថវិកា ចំនួន ៤.២០០ លានរៀល ( បួនពាន់ពីររយលានរៀលគត់ ) ពីជំពូក ៤០ ( ចំណាយផ្សេងៗ ) សង VAT មកជំពូក ១១ ( ចំណាយដំណើរការរដ្ឋបាល សំភារៈ និងការជួសជុលតូច ) របស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ២០០៤ ស្តីពីការបែងចែកចំណាយឥណទានថវិកាមួយភាគដប់ពីរបណ្តោះអាសន្ន ។

**មាត្រា២:** ការបែងចែកឥណទានថវិកាចំណាយផ្ទៃក្នុងជំពូកទាំងនេះ តាមប្រការ កថាខ័ណ្ឌ និង វាក្យខ័ណ្ឌ ត្រូវធ្វើឡើងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ សំរាប់ចំណាយដំណើរការរដ្ឋបាល ។

**មាត្រា៣:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ២២ ខែ វិច្ឆិកា ឆ្នាំ ២០០៤

ហ៊ុន សែន

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- កាលប្បវត្តិ - ឯកសារ

បានយកសេចក្តីជំរាបជូន
សម្តេចនាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា

ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ:..៦០៤.អនក្រ.តត

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

៙

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសអោយប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតី នៃ ស្ថាប័នជាតិ

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា .

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃ គណៈរដ្ឋមន្ត្រី .

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃ ព្រះរាជាណាចក្រកម្ពុជា .

-តាមសំណើរបស់ រដ្ឋមន្ត្រី ក្រសួងសាធារណការ និង ដឹកជញ្ជូន

## សម្រេច

**មាត្រា ១.** -

ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនមន្ត្រី នៃស្ថានឯកអគ្គរដ្ឋទូត សាធារណរដ្ឋប្រជាមានិតចិន ប្រចាំព្រះរាជាណាចក្រកម្ពុជា ចំនួន ០២រូប ដែលមានគុណបំណាច់ និង ស្នាដៃល្អ ក្នុងការចូលរួមការងារសាងសង់ផ្លូវជាតិ លេខ៧ ពីទីរួមខេត្តក្រចេះ ដល់ព្រំដែន កម្ពុជា-ឡាវ ដូចមានរាយនាមខាងក្រោម :-

| | | |
|---|---|---|
| ១-លោក | *PENG Gang* | ទីប្រឹក្សាសេដ្ឋកិច្ច នៃ ស្ថានឯកអគ្គរដ្ឋទូត |
| ២-លោក | *WANG Duo* | មន្ត្រីទទួលបន្ទុកកិច្ចការជំនួយ នៃ ស្ថានឯកអគ្គរដ្ឋទូត |

**មាត្រា ២.** -

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង រដ្ឋមន្ត្រីក្រសួងសាធារណការ និង ដឹកជញ្ជូន ត្រូវអនុវត្ត អនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ.ថ្ងៃទី ១៦ ខែវិច្ឆិកា ឆ្នាំ ២០០៤

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល:**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា ១ និង មាត្រា ២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

R 43

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៦០៥ អនក្រ.តត

## អនុក្រឹត្យ

## ស្តីពី

## ការតែងតាំងមន្ត្រីរាជការ

* * * *

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស / រកម / ០៧០៤ /០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/ ០៧០៤ /១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស / រកម / ០១៩៦ / ១០ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- បានឃើញព្រះរាជក្រម លេខ ០៦ /នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី សហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៤០១/០៨៥ ចុះថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីការទូតជាន់ខ្ពស់
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ

## ស ម្រេ ច

**មាត្រា ១ :** តែងតាំងលោកស្រី **ស៊ សៅរី** ជាអគ្គទីប្រឹក្សា ស្ថានឯកអគ្គរាជទូតកម្ពុជាប្រចាំសាធារណរដ្ឋប្រជាមានិតចិន ។

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួង សេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ ក្រសួង-ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួនត្រូវអនុវត្តអនុក្រឹត្យនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

*រាជធានីភ្នំពេញ, ថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ២០០៤*

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យសម្តេច និងឯកឧត្តមឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ២*
- *រាជកិច្ច*
- *ឯកសារ -កាលប្បវត្តិ*

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ៧០៨ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការតែងតាំងមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកត/០១៩៦/១៤ ចុះថ្ងៃទី ៣១ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងពត៌មាន
- បានឃើញអនុក្រឹត្យលេខ ៧០ អនក្រ.បក ចុះថ្ងៃទី ០៥ ខែ សីហា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួងពត៌មាន
- បានឃើញអនុក្រឹត្យលេខ ៦៣ អនក្រ.បក ចុះថ្ងៃទី ០៨ ខែ កញ្ញា ឆ្នាំ ២០០៣ ស្តីពីការគ្រប់គ្រងការអនុវត្តន៍ការផ្លាស់ប្តូរក្របខ័ណ្ឌ ឋានន្តរស័ក្តិ និងថ្នាក់ របស់មន្ត្រីរាជការស៊ីវិល
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងពត៌មាន

## សម្រេច

**មាត្រា ១** : តែងតាំងលោក **តៅ គឹមច័ន្ទរ័ត្ន** ជាអគ្គនាយករង នៃអគ្គនាយកដ្ឋានទីភ្នាក់ងារសារពត៌មានកម្ពុជា AKP របស់ក្រសួងពត៌មាន ។

**មាត្រា ២** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពត៌មាន រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួនត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ វិច្ឆិកា ឆ្នាំ ២០០៤*

**ហ៊ុន សែន**

**កន្លែងទទួល**

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ២*
- *ឯកសារ_កាលប្បវត្តិ*

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ២០៣ អនក្រ.បក [illegible]

## អនុក្រឹត្យ

## ស្តីពី

## ការកែសំរួលមាត្រា១ នៃអនុក្រឹត្យលេខ ៣៣ អនក្រ.បក ចុះថ្ងៃទី ០៣ ខែសីហា ឆ្នាំ ២០០៤ ស្តីពីការផ្ទេរក្របខ័ណ្ឌមន្ត្រីរាជការស៊ីវិល រវាងអតីតក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈនិងយុវនីតិសម្បទា អតីតក្រសួងកិច្ចការនារី និងអតីតយុទ្ធជន ក្រសួងអប់រំយុវជន និងកីឡា និងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ០៧០៤ / ១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញអនុក្រឹត្យលេខ ៣៣ អនក្រ.បក ចុះថ្ងៃទី ០៣ ខែ សីហា ឆ្នាំ ២០០៤ ស្តីពីការផ្ទេរក្របខ័ណ្ឌមន្ត្រីរាជការស៊ីវិល រវាងអតីតក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា អតីតក្រសួងកិច្ចការនារី និងអតីតយុទ្ធជន ក្រសួងអប់រំយុវជន និងកីឡា និងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

## សំរេច

**មាត្រា១** : ត្រូវបានផ្ទេរក្របខ័ណ្ឌមន្ត្រីរាជការស៊ីវិល ចំនួន ៤៩ នាក់ (ដូចមានក្នុងឧបសម្ព័ន្ធជូនភ្ជាប់) ក្នុងចំណោមមន្ត្រី រាជការស៊ីវិលចំនួន ៩៥៦ នាក់ ដែលមានចែងក្នុងមាត្រា១ នៃអនុក្រឹត្យលេខ ៣៣ អនក្រ.បក ចុះថ្ងៃទី ០៣ ខែ

សីហា ឆ្នាំ ២០០៤ ស្ដីពីការផ្ទេរក្របខ័ណ្ឌមន្ត្រីរាជការស៊ីវិល រវាងអតីតក្រសួងសង្គមកិច្ច ការងារ បណ្ដុះបណ្ដាលវិជ្ជាជីវៈ និងយុវនីតិសម្បទា អតីតក្រសួងកិច្ចការនារី និងអតីតយុទ្ធជន ក្រសួងអប់រំយុវជន និងកីឡា និងក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈអោយទៅបំរើការងារនៅក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។

**មាត្រា២** : ផ្ទេរភារកិច្ចលោក **ឈី សុគា** ពីប្រធានមន្ទីរការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈខេត្តសៀមរាប មកជាប្រធានមន្ទីរការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈខេត្តពោធិសាត់ ។

ផ្ទេរភារកិច្ចលោក **ហ៊ាន សុវណ្ណ** ពីប្រធានមន្ទីរការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈខេត្តឧត្ដរមានជ័យ មកជាប្រធានមន្ទីរការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈខេត្តកំពង់ធំ ។

**មាត្រា៣** : បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា៤** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រដ្ឋមន្ត្រីក្រសួងការងារនិងបណ្ដុះបណ្ដាលវិជ្ជាជីវៈ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការនៃក្រសួង ស្ថាប័នពាក់ព័ន្ធ អភិបាលខេត្ត-ក្រុងមានភារកិច្ចអនុវត្តតាមអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២២ ខែ ១១ ឆ្នាំ ២០០៤

នាយករដ្ឋមន្ត្រី

**ហ៊ុន សែន**

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្ដេច និងឯកឧត្ដមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៤
- រាជកិច្ច
- ឯកសារ - កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ៧០៩ អនក្រ.តត

## អនុក្រឹត្យ

## ស្តីពីការតែងតាំងមន្ត្រីរាជការ

៚ ✱ ៚

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកត/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែកក្កដា ឆ្នាំ ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញអនុក្រឹត្យលេខ ២៩ អនក្រ.បក ចុះថ្ងៃទី ២៣ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការបង្កើតខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា
- យោងតាមសំណើរបស់ឯកឧត្តមឧបនាយករដ្ឋមន្ត្រី **ស ខេង**

## សម្រេច

**មាត្រា ១ :** ត្រូវបានតែងតាំងលោក **សេង ផល្លី** ជាជំនួយការឯកឧត្តមឧបនាយករដ្ឋមន្ត្រី **ស ខេង** មានឋានៈស្មើ **អគ្គនាយករង** ជំនួសលោក **ចំនួ មរនា** ដែលត្រូវទៅបំរើការងារនៅក្រសួងផ្សេង ។

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័ន ដែលពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងមាត្រា ១ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ ២០០៤

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ៦០៩ អនក្រ.បក

## អនុក្រឹត្យ

## ស្តីពីការដាក់មន្ត្រីរាជការឱ្យឈប់បំរើការងារពីក្របខ័ណ្ឌរដ្ឋ

* * * * * * *

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតី នៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងផែនការ
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី២៦ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៥៥ អនក្រ.បក ចុះថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងផែនការ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងផែនការ

## សម្រេច

**មាត្រា ១ .-**

ត្រូវបានដាក់ឱ្យលោក **វន្ត សៀវគីមសេង** វរៈមន្ត្រីថ្នាក់លេខ ៤ បច្ចុប្បន្នអគ្គាធិការរង នៃអគ្គាធិ - ការដ្ឋានរបស់ក្រសួងផែនការ ឈប់បំរើការងារពីក្របខ័ណ្ឌរដ្ឋ ។

**មាត្រា ២ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងផែនការ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ ២០០៤

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- ឯកសារ - កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ៦១០ អនក្រ.តត

## អនុក្រឹត្យ
## ស្តីពីការតែងតាំងមន្ត្រីរាជការ

* * * * *

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី២៦ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

## សម្រេច

**មាត្រា ១ .-**

ត្រូវបានតែងតាំងលោក **ម៉ែន នុន** ជាប្រធាននាយកដ្ឋានក្សេត្រសាស្ត្រ និង កែលំអដីកសិកម្ម នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

**មាត្រា ២ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី២៣ខែវិច្ឆិកា ឆ្នាំ ២០០៤
**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ដូចមាត្រា ២
- ឯកសារ - កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៦១១ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការតែងតាំងមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃ គណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម លេខ នស/រកម/០១៩៦/១៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យ ប្រើច្បាប់ស្តីពីការបង្កើតក្រសួងពត៌មាន
- បានឃើញអនុក្រឹត្យ លេខ ៧០ អនក្រ.បក ចុះថ្ងៃទី ០៩ ខែ សីហា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងពត៌មាន
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងពត៌មាន

## សម្រេច

**មាត្រា ១:** តែងតាំង លោក **ម៉ែន សាម៉ន** ជាទីប្រឹក្សាក្រសួងពត៌មាន មានឋានៈស្មើ អគ្គនាយករង ។

**មាត្រា ២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពត៌មាន រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័ន ដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ០៣ ខែ ១១ ឆ្នាំ ២០០៤

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**កន្លែងទទួល :**

ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
  អគ្គលេខាធិការដ្ឋានរដ្ឋសភា
  អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
  ខុទ្ទកាល័យសម្តេច និងឯកឧត្តម ឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
  ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ៧៤០ សរណ

# សេចក្តីសម្រេច

# ស្តីពី

# ការកំណត់បទដ្ឋាននៃការប្រើប្រាស់ដីធ្លីនៅតំបន់១ និង តំបន់២ ក្នុងតំបន់រមណីយដ្ឋានសៀមរាប-អង្គរ

* * *

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានាដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២៦ ចុះថ្ងៃទី២៥ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីកិច្ចការពារបេតិកភណ្ឌវប្បធម៌
- បានឃើញព្រះរាជក្រឹត្យលេខ ០០១/នស ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ១៩៩៤ ស្តីពីការកំណត់ និងការចាត់ចែងគ្រប់គ្រងតំបន់សៀមរាប-អង្គរ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២៩៥/១២ ចុះថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ១៩៩៥ ស្តីពីការបង្កើតអាជ្ញាធរដើម្បីការពារតំបន់រមណីយដ្ឋាន និង រៀបចំតំបន់អង្គរ ហៅថា " អាជ្ញាធរអប្សរា"
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០១៩៩/១៨ ចុះថ្ងៃទី២២ ខែមករា ឆ្នាំ១៩៩៩ ស្តីពីការកែសម្រួលបទប្បញ្ញត្តិមួយចំនួននៃព្រះរាជក្រឹត្យលេខ នស/រកត/០២៩៥/១២ ចុះថ្ងៃទី ១៩ ខែកុម្ភៈ ឆ្នាំ១៩៩៥ ស្តីពីការ

បង្កើតអាជ្ញាធរដើម្បីការពាររមណីយដ្ឋាន និងរៀបចំតំបន់អង្គរហៅថា " អាជ្ញាធរអប្សរា " ឱ្យស្របទៅតាមបទប្បញ្ញត្តិនៃព្រះរាជក្រឹត្យលេខ នស/រកត/១២៩៧/៩១ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៩៧ ស្តីពីលក្ខន្តិកៈគតិយុត្តិនៃគ្រឹះស្ថានសាធារណៈរដ្ឋបាល

- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៤/២៨៧ ចុះថ្ងៃទី ២០ ខែ កញ្ញា ឆ្នាំ ២០០៤ ស្តីពីការកែសំរួលមាត្រា៤ និងមាត្រា៥ នៃព្រះរាជក្រឹត្យលេខ នស /រកត/ ០១៩៩ /១៨ ចុះថ្ងៃទី ២២ ខែ មករា ឆ្នាំ ១៩៩៩ ស្តីពីការកែសម្រួលបទប្បញ្ញតិមួយចំនួននៃព្រះរាជក្រឹត្យលេខ នស/រកត/ ០២៩៥/១២ ចុះថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ១៩៩៥ ស្តីពីការបង្កើតអាជ្ញាធរអប្សរា

-បទបញ្ជាលេខ០២ បប ចុះថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ២០០៤ របស់រាជរដ្ឋាភិបាល ស្តីពីការទប់ស្កាត់អំពីអនាធិបតេយ្យនៅតំបន់រមណីយដ្ឋានអង្គរ ខេត្តសៀមរាប

-តាមការងារចាំបាច់ចំពោះមុខនៅតំបន់រមណីយដ្ឋានសៀមរាប-អង្គរ

## សម្រេច

**ប្រការ១.-**

ដីធ្លីទាំងអស់ដែលស្ថិតនៅក្នុងតំបន់១ និងតំបន់២ ក្នុងតំបន់រមណីយដ្ឋានសៀមរាប-អង្គរ គឺជាដីសាធារណៈរបស់រដ្ឋ ដែលអាជ្ញាធរអប្សរា មានភារកិច្ច កាតព្វកិច្ចត្រូវគ្រប់គ្រង ថែរក្សា និងអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាព ។

**ប្រការ២.-**

ត្រូវបានហាមឃាត់ការប្រើប្រាស់ដីធ្លីនៅក្នុងតំបន់១ និងតំបន់២ ក្នុងតំបន់រមណីយដ្ឋានសៀមរាប-អង្គរ ដូចតទៅ ៖

- ប្រជាពលរដ្ឋដែលមានលំនៅដ្ឋាន និង[illegible] អាចនៅរស់នៅតទៅទៀតបាន ដោយ[illegible] [illegible]

[illegible] ជំនួសផ្ទះ[illegible] [illegible] អាជ្ញាធរអប្សរា

- [illegible] ដើម្បីដោះស្រាយជីវភាព [illegible] [illegible] ជាដើម ។ល។

**ប្រការ៣.-**

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ត្រូវណែនាំជាបន្ទាន់ដល់មន្ទីររៀបចំដែនដី នគររូបនីយកម្ម និងសំណង់ ខេត្តសៀមរាបអោយអនុវត្តនីតិវិធីធ្វើការផ្ទេរសិទ្ធិលើដីធ្លី លំនៅដ្ឋានក្នុងតំបន់១ និងតំបន់២ ក្រោយពីមានការបញ្ជាក់ពីសមត្ថកិច្ចនៃអាជ្ញាធរអប្សរាដែលជាអ្នកមានភារកិច្ច ភាគព្វកិច្ចត្រូវគ្រប់គ្រង ថែរក្សា និងអភិវឌ្ឍន៍ប្រកបដោយចីរភាពនៅតំបន់រមណីយដ្ឋានសៀមរាប-អង្គរ ជាពិសេសតំបន់១ និងតំបន់ ២ នេះ ។

**ប្រការ៤.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយពីសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍ ។

**ប្រការ៥.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ សហរដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រី រដ្ឋលេខាធិការនៃក្រសួង ស្ថាប័ន អគ្គនាយកអគ្គនាយកដ្ឋាន នៃអាជ្ញាធរអប្សរា និងអភិបាលខេត្តសៀមរាប ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ២០០៤

នាយករដ្ឋមន្ត្រី

**ហ៊ុន សែន**

**<u>កន្លែងទទួល</u>**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ ៥
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ...៦៧០...សសរ

**សេចក្តីសំរេច**
**ស្តីពី**
ការបង្កើតគណៈកម្មការអន្តរក្រសួង
ដើម្បីរៀបចំខួប ១០ ឆ្នាំ នៃការរស់ឡើងវិញលើវិស័យខ្លែងខ្មែរ
ថ្ងៃទី ១១,១២,១៣ ខែ ធ្នូ ឆ្នាំ ២០០៤

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
  បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម លេខ នស/រកម/០១៩៦/០២ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- បានឃើញអនុក្រឹត្យលេខ ៦២ អនក្រ.បក ចុះថ្ងៃទី ១៤ ខែ តុលា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- យោងតាមការងារចាំបាច់ចំពោះមុខ

**សំរេច**

**ប្រការ ១ :** បង្កើតគណៈកម្មការអន្តរក្រសួងមួយ ដើម្បីរៀបចំខួប ១០ ឆ្នាំ នៃការរស់ឡើងវិញលើវិស័យខ្លែងខ្មែរ ។

**ប្រការ ២ :** សមាសភាពគណៈកម្មការអន្តរក្រសួង មានដូចតទៅ :

| | | | |
|---|---|---|---|
| ១-អ្នកអង្គម្ចាស់ | **ស៊ីសុវត្ថិ ប៊ុណ្ណារ៉ា ស៊ីរីវុឌ្ឍ** | រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ | ប្រធាន |
| ២-ឯកឧត្តម | **យឹម សារិទ្ធ** | រដ្ឋលេខាធិការ ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ | អនុប្រធាន |
| ៣-ឯកឧត្តម | **រស់ ម៉េង** | រដ្ឋលេខាធិការ ក្រសួង ទេសចរណ៍ | អនុប្រធាន |
| ៤-ឯកឧត្តម | **ស៊ូ ស៊ុម** | អនុរដ្ឋលេខាធិការ ក្រសួង ពត៌មាន | សមាជិក |
| ៥-ឯកឧត្តម | **សោម សុគន្ធ** | អនុរដ្ឋលេខាធិការ ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ | សមាជិក |
| ៦-ឯកឧត្តម | **អ៊ុក សុជាតិ** | អនុរដ្ឋលេខាធិការ ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ | សមាជិក |

៧-ឯកឧត្តម ង៉ែត ឥសាន្ត អនុរដ្ឋលេខាធិការ ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ សមាជិក

៨-ឯកឧត្តម សោម សុផលនិស្ស អនុរដ្ឋលេខាធិការ ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ សមាជិក

៩-ឯកឧត្តម នូយ គៀង សាកលវិទ្យាធិការនៃសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ សមាជិក

១០-ឯកឧត្តម ស៊ុំ សារ៉េត អគ្គនាយកវប្បធម៌ និងវិចិត្រសិល្បៈ សមាជិក

១១ ឯកឧត្តម ជាឡូ សុខ អគ្គនាយកបេតិកភណ្ឌវប្បធម៌ សមាជិក

១២-ឯកឧត្តម ម៉ប់ សារិន អភិបាលរងរាជធានីភ្នំពេញ សមាជិក

១៣-លោក ឧត្តមសេនីយ៍ទោ **សួន ឈាងលី** ប្រធាននាយកដ្ឋានសន្តិសុខ ក្រសួងមហាផ្ទៃ សមាជិក

១៤-លោក ស៊ុន ម៉ិនឡឿន ប្រធាននាយកដ្ឋានរដ្ឋបាលនៃក្រសួងការបរទេស
និងសហប្រតិបត្តិការអន្តរជាតិ សមាជិក

១៥-លោក ប៉ែន សារិន ប្រធាននាយកដ្ឋាន [illegible] សមាជិក [illegible]

១៦-លោក ម៉ៅ កេង ប្រធាននាយកដ្ឋានសិល្បៈទស្សនីយភាព សមាជិក

**ប្រការ ៣ :** គណៈកម្មការអន្តរក្រសួង មានភារកិច្ចស្វែងរកចំណូលដើម្បីផ្គត់ផ្គង់ដំណើរការរៀបចំពិធីបណ្តោះខ្លែងអបអរសាទរខួប ១០ ឆ្នាំ នៃការរស់ឡើងវិញវិស័យខ្លែងខ្មែរ ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី ១១-១២-១៣ ខែ ធ្នូ ឆ្នាំ ២០០៤ ។

**ប្រការ ៤ :**- គណៈកម្មការអន្តរក្រសួង មានសិទ្ធិបង្កើតអនុគណៈកម្មការ និងលេខាធិការជាជំនួយការអោយគណៈកម្មការអន្តរក្រសួង ។

- អនុគណៈកម្មការនិងលេខាធិការត្រូវប្រើប្រាស់មន្ត្រីជំនាញតាមអង្គភាពខ្លួនដោយរៀបចំបញ្ជីឈ្មោះសមាជិកស្នើសុំសេចក្តីសំរេចពីគណៈកម្មការអន្តរក្រសួង ។

**ប្រការ ៥ :**- រាល់ការចំណាយរបស់អនុគណៈកម្មការ និងលេខាធិការ ត្រូវធ្វើគំរោងលំអិត និងសុំសេចក្តីសំរេចពីគណៈកម្មការអន្តរក្រសួង ។

**ប្រការ ៦ :**- គណៈកម្មការអន្តរក្រសួង មានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ។

**ប្រការ ៧ :**- រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ រដ្ឋមន្ត្រីក្រសួងទេសចរណ៍ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួងស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដែលមានចែងក្នុងប្រការ ២ ត្រូវអនុវត្តសេចក្តីសំរេចនេះ អោយមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅរហូតដល់ចប់ពិធី ។

*រាជធានីភ្នំពេញ, ថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០០៤*

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**ចម្លងជូន**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យ សម្តេចនាយករដ្ឋមន្ត្រី
- ដូចប្រការ ៧
- ឯកសារ - កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:**...៧៧...ស.សរ

# សេចក្តីសំរេច

## ស្តីពី

## ការបង្កើតក្រុមការងារបច្ចេកទេសចំរុះ រាជរដ្ឋាភិបាល-ប្រទេសម្ចាស់ជំនួយ លើវិស័យមីន

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ០៧០៤ / ១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០០/១៦០ ចុះថ្ងៃទី ០៤ ខែ កញ្ញា ឆ្នាំ ២០០០ ស្តីពីការបង្កើតអាជ្ញាធរកម្ពុជាគ្រប់គ្រងសកម្មភាពកំចាត់មីន និងសង្គ្រោះជនពិការដោយសារមីន
- បានឃើញអនុក្រឹត្យលេខ ៧៦ អនក្រ/បក ចុះថ្ងៃទី ០៨ ខែ សីហា ឆ្នាំ ២០០១ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អាជ្ញាធរកម្ពុជាគ្រប់គ្រងសកម្មភាពកំចាត់មីន និងសង្គ្រោះជនពិការដោយសារមីន
- យោងតាមតំរូវការចាំបាច់របស់រាជរដ្ឋាភិបាល

## សំរេច

**ប្រការ១ :** បង្កើតក្រុមការងារបច្ចេកទេសចំរុះ រាជរដ្ឋាភិបាល-ប្រទេសម្ចាស់ជំនួយ លើវិស័យមីន ដែលមានសមាសភាពដូចខាងក្រោម:

| | | |
|---|---|---|
| ១-ឯកឧត្តម **ប្រាក់ សុខុន** | រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី | ប្រធាន |
| ២-ឯកឧត្តម **សួស គង់** | រដ្ឋលេខាធិការក្រសួងអភិវឌ្ឍន៍ជនបទ | សមាជិក |
| ៣-ឯកឧត្តម **ខឹម សោភ័ណ** | អគ្គនាយកមជ្ឈមណ្ឌលសកម្មភាពកំចាត់មីនកម្ពុជា | សមាជិក |
| ៤-ឯកឧត្តម **សែម សុវណ្ណានី** | អគ្គលេខាធិការរងអាជ្ញាធរមីនកម្ពុជា ទទួលបន្ទុកកិច្ចការបោសសំអាតមីននៃកងយោធពលខេមរភូមិន្ទ | សមាជិក |

| | | | |
|---|---|---|---|
| ៥-ឯកឧត្តម | **សេក សេដ្ឋា** | អគ្គនាយកសុរិយោដី និងភូមិសាស្ត្រ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | សមាជិក |
| ៦-ឯកឧត្តម | **ឡេង សុជា** | អគ្គលេខាធិការរង អាជ្ញាធរមីនកម្ពុជា | សមាជិក |
| ៧-ឯកឧត្តម | **ហេង រតនា** | អគ្គនាយករង មជ្ឈមណ្ឌលសកម្មភាពកំចាត់មីនកម្ពុជា | សមាជិក |
| ៨-ឯកឧត្តម | **ស ចាន់ធី** | ជំនួយការសម្តេចនាយករដ្ឋមន្ត្រី | សមាជិក |
| ៩-លោក | **នេត សុផល** | ប្រធាននាយកដ្ឋានផែនការ និងត្រួតពិនិត្យអាជ្ញាធរមីនកម្ពុជា | សមាជិក |
| ១០-លោក | **ចាន់ រដ្ឋា** | ប្រធាននាយកដ្ឋានទំនាក់ទំនង អាជ្ញាធរមីនកម្ពុជា | សមាជិក |

**ប្រការ២** : ក្រុមការងារបច្ចេកទេសចំរុះមានភារកិច្ចសម្របសម្រួលការងាររវាងរាជរដ្ឋាភិបាល និងប្រទេសផ្តល់ជំនួយលើវិស័យមីននៅកម្ពុជា។

**ប្រការ៣** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ សហរដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រី រដ្ឋលេខាធិការ ក្រសួង ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួន ដែលមានចែងក្នុងប្រការមួយ ត្រូវអនុវត្តសេចក្តីសំរេចនេះ ឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ វិច្ឆិកា ឆ្នាំ ២០០៤*

នាយករដ្ឋមន្ត្រី

**ហ៊ុន សែន**

**កន្លែងទទួល** :
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច និងឯកឧត្តម ឧបនាយករដ្ឋមន្ត្រី
- ដូចចែងក្នុងប្រការ ៣
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ៧៣ . សសរ

## សេចក្តីសម្រេច

## ស្តីពី

## ការបង្កើតគណៈកម្មការ ដើម្បីធ្វើការសម្របសម្រួលជាមួយធនាគារពិភពលោក ក្នុងការផ្តល់ស្ថិតិ និងព័ត៌មានផ្សេងៗជូនថ្នាក់ខេត្តក្រុង ដើម្បីធ្វើការវាយតម្លៃលើបរិស្ថានវិនិយោគ និងលើស្ថានភាពជារួមនៃប្រទេសកម្ពុជា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ០៧០៤ / ១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

យោងតាមតម្រូវការចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

**ប្រការ ១ :** បង្កើតគណៈកម្មការ ដើម្បីធ្វើការសម្របសម្រួល និងផ្តល់ទិន្នន័យពាក់ព័ន្ធនយោបាយ និងសេដ្ឋកិច្ច-សង្គម ដើម្បីផ្តល់ជូនទីភ្នាក់ងារកម្រិតថ្នាក់ សម្រាប់ធ្វើជាមូលដ្ឋានក្នុងកម្រិតថ្នាក់ប្រទេសកម្ពុជា ដែលមានសមាសភាពដូចខាងក្រោម :

១- ឯកឧត្តម **សេង លឹមនៅ** រដ្ឋលេខាធិការ ទីស្តីការគណៈរដ្ឋមន្ត្រី ប្រធាន

២- ឯកឧត្តម **ហង់ជួន ណារ៉ុន** អគ្គលេខាធិការ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អនុប្រធាន

៣-ឯកឧត្តម **សុខ ចិន្តា** អគ្គលេខាធិការ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា សមាជិក

៤- ឯកឧត្តម **សយ សុខា** អគ្គលេខាធិការ ក្រុមសង្កេតការណ៍សេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ សមាជិក

៥- ឯកឧត្តម **ជា ច័ន្ទដេត** នាយកខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សមាជិក

| | | | |
|---|---|---|---|
| ៦- ឯកឧត្តម | **ម៉ៅ ថូរ៉ា** | អនុរដ្ឋលេខាធិការ ក្រសួងពាណិជ្ជកម្ម | សមាជិក |
| ៧- ឯកឧត្តម | **ហ៊ូ តាំងអេង** | អនុរដ្ឋលេខាធិការ ក្រសួងផែនការ | សមាជិក |
| ៨- ឯកឧត្តម | **សក់ សេដ្ឋា** | អគ្គនាយករដ្ឋបាល ក្រសួងមហាផ្ទៃ | សមាជិក |
| ៩- លោក | **ឡុញ ហៃ** | អគ្គនាយករង ធនាគារជាតិនៃកម្ពុជា | សមាជិក |

**ប្រការ ២** : គណៈកម្មការ មានភារកិច្ចប្រមូលទិន្នន័យពាក់ព័ន្ធនយោបាយ និងសេដ្ឋកិច្ច-សង្គម ដើម្បីផ្ដល់ជូនភ្នាក់ងារកម្រិតថ្នាក់ តាមរយៈធនាគារឥណទានស៊ីសហ្វីសបុសតុន។ គណៈកម្មការនេះ អាចមានក្រុមការងារមួយ សម្រាប់ជាជំនួយការក្នុងការប្រមូលទិន្នន័យ និងការងារពាក់ព័ន្ធផ្សេងៗ។

**ប្រការ ៣** : គណៈកម្មការ មានភារកិច្ចសហការជាមួយធនាគារឥណទានស៊ីស និងពិភាក្សាលើលទ្ធផលនៃការវាយតម្លៃ។

**ប្រការ ៤** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សហប្រធានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រីក្រសួងផែនការ សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ទេសាភិបាលធនាគារជាតិនៃកម្ពុជា និងសាមីខ្លួន ដែលមានចែងក្នុងប្រការ ១ ត្រូវអនុវត្តសេចក្ដីសម្រេចនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

*រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ វិច្ឆិកា ឆ្នាំ ២០០៤*

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

កន្លែងទទួល :

- *ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យសម្ដេច និងឯកឧត្តមឧបនាយករដ្ឋមន្ត្រី*
- *ដូចចែងក្នុងប្រការ ៤*
- *ឯកសារ-កាលប្បវត្តិ* ✓

**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

លេខ ៤៦៩ សហវ.ប្រក

រាជធានីភ្នំពេញ, ថ្ងៃទី ១៧ ខែវិច្ឆិកា ឆ្នាំ ២០០៤

**ប្រកាស**

**ស្តីពី**

**ការកែសម្រួលសមាសភាពគណៈកម្មាធិការដឹកនាំការអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ**

- បានឃើញ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/ រកត/ ០៧០៤ /១២៤ ចុះ ថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រមលេខ ០២ នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០១៩៦/១០ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញ អនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី ២០ខែ សីហា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញ អនុក្រឹត្យលេខ ២៥ អនក្រ.បក ចុះ ថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ១៩៩៧ ស្តីពីការបង្កើតគណៈកម្មាធិការសំរាប់គោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញឯកសារចក្ខុវិស័យ និងផែនការសំរាប់ការអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុពីឆ្នាំ ២០០១-២០១០ ដែលត្រូវបានអនុម័តដោយរាជរដ្ឋាភិបាលកាលពីថ្ងៃទី ២៤ ខែ សីហា ឆ្នាំ ២០០១
- បានឃើញលិខិតរបស់ក្រសួងយុត្តិធម៌ លេខ ៨២៦. បបបកយ/២០០៤ ចុះថ្ងៃទី ១៨ ខែ សីហា ឆ្នាំ២០០៤ ស្តីពីការចាត់បញ្ជូនតំណាងដើម្បីចូលរួមក្នុងគណៈកម្មាធិការដឹកនាំការអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ
- បានឃើញលិខិតរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា លេខ ០៧៣ ស.អ.យ ចុះថ្ងៃទី ១៣ ខែ សីហា ឆ្នាំ ២០០៤ ស្តីពីការចាត់បញ្ជូនតំណាងដើម្បីចូលរួមក្នុងគណៈកម្មាធិការដឹកនាំការអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ
- បានឃើញលិខិតរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ លេខ ០៨១ កបវ ចុះថ្ងៃទី ១៦ ខែ សីហា ឆ្នាំ ២០០៤ ស្តីពីការចាត់បញ្ជូនតំណាងដើម្បីចូលរួមក្នុងគណៈកម្មាធិការដឹកនាំការអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ
- បានឃើញប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ លេខ ២៤៨ សហវ.ចុះ ថ្ងៃទី ០៣ ខែ មេសា ឆ្នាំ ២០០២ ស្តីពីការបង្កើតគណៈកម្មាធិការដឹកនាំការអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ

# សំរេច

**ប្រការ ១** : កែសម្រួលសមាសភាពគណៈកម្មាធិការដឹកនាំ (Steering Committee) និងក្រុមការងារបច្ចេកទេស (Technical Working Group) សំរាប់ការអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ (Financial Sector Development) ដែលមានដូចខាងក្រោម ÷

## ក . សមាសភាពថ្មីរបស់គណៈកម្មាធិការដឹកនាំ

| | | |
|---|---|---|
| ១- ឯកឧត្តម **ជា ចាន់តូ** | ទេសាភិបាលធនាគារជាតិ នៃកម្ពុជា | ប្រធាន |
| ២- ឯកឧត្តម **ជា ប៉េងឈាង** | រដ្ឋលេខាធិការ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | អនុប្រធាន |
| ៣- ឯកឧត្តម **ស៊ុំ សន្និសិទ្ធ** | អគ្គលេខាធិការធនាគារជាតិ នៃកម្ពុជា | លេខាធិការ |
| ៤- ឯកឧត្តម **នឹម ថូត** | រដ្ឋលេខាធិការ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | សមាជិក |
| ៥- ឯកឧត្តម **ហង់ ជួនណារ៉ុន** | អគ្គលេខាធិការ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ៦- ឯកឧត្តម **សុខ ចិន្តា** | អគ្គលេខាធិការ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | សមាជិក |
| ៧- លោកជំទាវ **តាល់ ណៃរ៉ុម** | អគ្គនាយក ធនាគារជាតិនៃកម្ពុជា | សមាជិក |
| ៨- ឯកឧត្តម **សួស សម្បត្តិ** | អគ្គនាយក នៃអគ្គនាយកដ្ឋានរដ្ឋបាល ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | សមាជិក |
| ៩- លោក **ពេជ្រ ឫទ្ធី** | អគ្គនាយករងបច្ចេកទេសក្រសួងពាណិជ្ជកម្ម | សមាជិក |
| ១០- លោក **ឃួន វ៉ានីន** | អគ្គនាយករងកិច្ចការរដ្ឋបាល និងហិរញ្ញវត្ថុ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | សមាជិក |
| ១១- លោក **តុខ ពាច** | ប្រធាននាយកដ្ឋានរដ្ឋបាលនិងកិច្ចការទូទៅ ក្រសួងយុត្តិធម៌ | សមាជិក |

## ខ . សមាសភាពថ្មីរបស់ក្រុមការងារបច្ចេកទេស

| | | |
|---|---|---|
| ១. ឯកឧត្តម **ហង់ ជួនណារ៉ុន** | អគ្គលេខាធិការ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ប្រធាន |
| ២. លោកជំទាវ **តាល់ ណៃរ៉ុម** | អគ្គនាយក ធនាគារជាតិនៃកម្ពុជា | អនុប្រធាន |
| ៣. លោក **ម៉ី ទារ៉ន់** | ប្រធាននាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | អនុប្រធាន |
| ៤. លោក **មិញ ឆានកុសល** | អនុប្រធានទី១ នាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | លេខាធិការ |

| | | |
|---|---|---|
| ៥ . លោក **ចាន់ សុធី** | ប្រធាននាយកដ្ឋានវិនិយោគនិងសហប្រតិបត្តិការ<br>ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ៦ . លោក **អន សុផានណារ៉ា** | ប្រធាននាយកដ្ឋាននីតិកម្ម និងព្យាបារវិនិយោគ<br>ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | សមាជិក |
| ៧ . លោក **ផាន់ ហុះ** | ប្រធាននាយកដ្ឋានត្រួតពិនិត្យ<br>ធនាគារជាតិនៃកម្ពុជា | សមាជិក |
| ៨ . លោក **សៀង សុឃុនឌី** | ប្រធាននាយកដ្ឋានហិរញ្ញវត្ថុ និងផ្គត់ផ្គង់<br>ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | សមាជិក |
| ៩ . លោកស្រី **ខួន សុខា** | អនុប្រធាននាយកដ្ឋានស្រាវជ្រាវសេដ្ឋកិច្ច<br>ធនាគារជាតិនៃកម្ពុជា | សមាជិក |
| ១០ . លោក **ម៉ូ ច័ន្ទតិរ៉ុ** | អនុប្រធាននាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ<br>ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ១១ . លោក **ការ៉ង សុជាតិ** | អនុប្រធាននាយកដ្ឋានគណនេយ្យ<br>ក្រសួងពាណិជ្ជកម្ម | សមាជិក |
| ១២ . លោក **អ៊ុន ម៉ុនថា** | អនុប្រធាននាយកដ្ឋានពាណិជ្ជកម្មក្នុងប្រទេស<br>ក្រសួងពាណិជ្ជកម្ម | សមាជិក |
| ១៣ . លោក **ឆៅ រ័ត្ន** | អនុប្រធាននាយកដ្ឋានហិរញ្ញវត្ថុ និងផ្គត់ផ្គង់<br>ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | សមាជិក |
| ១៤ . លោក **យឹម សំអុល** | អនុប្រធាននាយកដ្ឋានហិរញ្ញវត្ថុ<br>ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | សមាជិក |
| ១៥ . លោក **សុខ សារុន** | អនុប្រធាននាយកដ្ឋានរដ្ឋបាលនិងកិច្ចការទូទៅ<br>ក្រសួងយុត្តិធម៌ | សមាជិក |
| ១៦ . លោក **នង ពិសិដ្ឋ** | ប្រធានការិយាល័យទីផ្សារហិរញ្ញវត្ថុ<br>ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ១៧ . លោក **ឆាយ រតនៈ** | ប្រធានការិយាល័យធានារ៉ាប់រង<br>ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ១៨ . លោក **ម៉ែន សុភាព** | ប្រធានការិយាល័យសំភារៈ និងភស្តុភារ<br>ក្រសួងយុត្តិធម៌ | សមាជិក |
| ១៩ . លោក **សេស សុធីរ** | ប្រធានការិយាល័យគ្រប់គ្រងអាជីវកម្មនិងប្រកួតប្រជែង<br>ក្រសួងពាណិជ្ជកម្ម | សមាជិក |

| | | |
|---|---|---|
| ២០. លោក ទុិល ណារ៉ាក់ | ប្រធានការិយាល័យគ្រប់គ្រងជំនួយពហុភាគី ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | សមាជិក |
| ២១. លោកស្រី ឈ គីមអុី | ប្រធានការិយាល័យ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | សមាជិក |
| ២២. លោក យស សំរុល | ប្រធានការិយាល័យសំភារៈ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | សមាជិក |
| ២៣. លោកស្រី យូន នទីវណ្ណា | អនុប្រធានការិយាល័យ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | សមាជិក |
| ២៤. លោក ស៊ុំ ពិរះសដ្ឋ | អនុប្រធានការិយាល័យគណនេយ្យ ក្រសួងយុត្តិធម៌ | សមាជិក |

ប្រការ ២: គណៈកម្មាធិការដឹកនាំការអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុមានភារកិច្ចដូចខាងក្រោម:

- សំរបសំរួលចំពោះជំនួយឧបត្ថម្ភដែលម្ចាស់ជំនួយបានផ្តល់សំរាប់ការអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ
- តាមដាននិងជំរុញការអភិវឌ្ឍន៍ផែនការយុទ្ធសាស្រ្តសំរាប់អភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ
- ពិនិត្យនិងផ្តល់ការណែនាំស្តីពីគោលនយោបាយហិរញ្ញវត្ថុនិងថវិកាសំរាប់អភិវឌ្ឍវិស័យហិរញ្ញវត្ថុ
- រៀបចំយុទ្ធសាស្រ្តផែនការសកម្មភាព និងយន្តការគៀងគរប្រភពធនធានព្រមទាំងការបែងចែកធនធានហិរញ្ញវត្ថុសំរាប់វិស័យនេះ
- ពិនិត្យនិងពង្រឹងប្រព័ន្ធរៀបចំផែនការថវិកា និងការគ្រប់គ្រងធនធានហិរញ្ញវត្ថុ ដោយសំរបសំរួលផែនការទាំងនេះទៅនឹងផែនការកសាងសមត្ថភាពក្នុងវិស័យអភិវឌ្ឍន៍ហិរញ្ញវត្ថុ
- ធ្វើការចរចា និងចុះហត្ថលេខាលើអនុស្សរណៈនានាពាក់ព័ន្ធជាមួយជំនួយបច្ចេកទេស និងឥណទានជាមួយធនាគារអភិវឌ្ឍអាស៊ីលើវិស័យនេះ
- ធ្វើរបាយការណ៍ជាទៀងទាត់ជូនគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជូនរាជរដ្ឋាភិបាលអំពីការវិវត្តន៍នៃដំណើរការអនុវត្តន៍ផែនការយុទ្ធសាស្រ្តសំរាប់អភិវឌ្ឍវិស័យហិរញ្ញវត្ថុ

ប្រការ ៣: ក្រុមការងារបច្ចេកទេស ត្រូវបំពេញការងារក្រោមការណែនាំរបស់គណៈកម្មាធិការដឹកនាំការអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ និងមានភារកិច្ចដូចតទៅ:

- ធ្វើការងារជាមួយក្រុមជំនួយបច្ចេកទេស ដើម្បីជំរុញការអនុវត្តន៍ផែនការយុទ្ធសាស្រ្តសំរាប់អភិវឌ្ឍវិស័យហិរញ្ញវត្ថុ និង ក្នុងកិច្ចព្រមព្រៀងឥណទានអោយទទួលបានជោគជ័យ
- ជំនួយការអោយគណៈកម្មាធិការដឹកនាំការអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ក្នុងការតាមដាន និងត្រួតពិនិត្យនូវការអនុវត្តន៍ការងារប្រចាំថ្ងៃរបស់ក្រុមប្រតិបត្តិប្រចាំសាមុីស្ថាប័ននីមួយៗ
- សំរបសំរួលអោយមានការឯកភាពគ្នារវាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ធនាគារជាតិនៃកម្ពុជា ក្រសួងពាណិជ្ជកម្ម ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា លើកលំបញ្ហាដែលពាក់ព័ន្ធទៅនឹង:

- ហិរញ្ញប្បទានសំរាប់ការអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ
- ការគ្រប់គ្រងហិរញ្ញវត្ថុសំរាប់ការអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ និង
- ការត្រួតពិនិត្យលើការអនុវត្តន៍ការងារគ្រប់គ្រងហិរញ្ញវត្ថុដែលកំពុងប្រើប្រាស់

- ធ្វើរបាយការណ៍ជាទៀងទាត់ជូនគណៈកម្មាធិការដឹកនាំការអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុអំពីការវិវត្តន៍នៃផែនការយុទ្ធសាស្ត្រសំរាប់អភិវឌ្ឍវិស័យហិរញ្ញវត្ថុ

**ប្រការ ៤:** ក្រសួង ស្ថាប័នពាក់ព័ន្ធខាងលើ ត្រូវបង្កើតក្រុមប្រតិបត្តិរបស់ខ្លួនដើម្បីអនុវត្តគំរោងប្រចាំថ្ងៃរបស់ក្រសួង ឬ ស្ថាប័នសាមីដែលមានចែងក្នុងឯកសារចក្ខុវិស័យ និង ផែនការយុទ្ធសាស្ត្រសំរាប់អភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ និងជាចំណុចសំរាប់ធ្វើទំនាក់ទំនងអន្តរស្ថាប័នលើការងារនេះ ។

**ប្រការ ៥:** គណៈកម្មាធិការដឹកនាំការអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ មានលេខាធិការដ្ឋាននៅធនាគារជាតិ នៃកម្ពុជា និងក្រុមការងារបច្ចេកទេសមានលេខាធិការដ្ឋាននៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

**ប្រការ ៦:** សមាជិកនៃគណៈកម្មាធិការដឹកនាំការអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ និងក្រុមការងារបច្ចេកទេសទាំងអស់ត្រូវចូលរួមប្រជុំពាក់ព័ន្ធនឹងការងារអភិវឌ្ឍវិស័យហិរញ្ញវត្ថុតាមការកោះអញ្ជើញរបស់ប្រធាន ។

**ប្រការ ៧:** អគ្គលេខាធិការ នាយកខុទ្ទកាល័យ នាយកដ្ឋានក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ព្រមទាំងសាមីខ្លួនដូចប្រការ ០១ ត្រូវទទួលបន្ទុកអនុវត្តតាមប្រកាសនេះ អោយមានប្រសិទ្ធិភាពខ្ពស់ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

**ទេសរដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**
**និងជាប្រធានគណៈកម្មាធិការសំរាប់គោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**គាត ឈន់**

**<u>ចំលងជូន:</u>**

- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ទីស្តីការគណៈរដ្ឋមន្ត្រី
  " ដើម្បីជូនជ្រាប ដូចក្នុងប្រការ ៣
- ឯកសារ- កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**KINGDOM OF CAMBODIA**

Nation - Religion - King

**ក្រសួងពាណិជ្ជកម្ម**

**Ministry of Commerce**

No ២៣៣ MOC / M 2004

រាជធានីភ្នំពេញ, ថ្ងៃទី ១៩ ខែ វិច្ឆិកា ឆ្នាំ ២០០៤

## ប្រកាស

## ស្តីពីស្ថានភាពរោងចក្រកាត់ដេរ

## LUEN THAI GARMENT (CAMBODIA) CO., LTD.

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២ នស.៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្តីពីការរៀបចំ និង ការប្រព្រឹត្ត ទៅរបស់ គណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំង រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើ ច្បាប់ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យ លេខ ៥៤ អនក្របក ចុះថ្ងៃទី ២២ ខែកញ្ញា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំ និង ការប្រព្រឹត្ត ទៅរបស់ក្រសួងពាណិជ្ជកម្ម
- បានឃើញការចាំបាច់របស់ក្រសួង

## សម្រេច

**ប្រការ ១ :** ចាត់ទុកថាបាន **បិទទ្វារជាបណ្តោះអាសន្ន** រោងចក្រកាត់ដេរសំលៀកបំពាក់ LUEN THAI GARMENT (CAMBODIA) CO., LTD. ដែលគ្មានសកម្មភាពចំពោះមុខដោយមាន មូលហេតុផ្សេងៗ ប៉ុន្តែ ឧបករណ៍ផលិតកម្ម និង គ្រឿងម៉ាស៊ីននៅរក្សាដដែលហើយកម្មករត្រូវ បានបញ្ឈប់ពីការងារជាបណ្តោះអាសន្ន ។ រោងចក្រកាត់ដេរសំលៀកបំពាក់នោះនឹងត្រូវលប់ចេញ ពីតារាង GSP នៃអ្នកមានសិទ្ធនាំចេញនៅនាយកដ្ឋានប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម ។ ការបែងចែក កូតាផ្សេងៗ (បើមាន) នឹងត្រូវផ្អាក ។ រោងចក្រខាងលើនេះ អាចទទួលបានសិទ្ធ នាំចេញសាជាថ្មី ប្រសិនបើរោងចក្រនោះបន្តសកម្មភាពរបស់ខ្លួនវិញក្នុងរយៈពេល ៣ ខែបន្ទាប់ ។

ប្រសិនបើរោងចក្រនោះមិនបានបន្តសកម្មភាពរបស់ ខ្លួនក្នុងរយៈពេល ៣ ខែបន្ទាប់ រោងចក្រនោះនឹងត្រូវចាត់ទុកថាបានបិទទ្វារជាស្ថាពរ ។ ការចុះបញ្ជីពាណិជ្ជកម្មនៅក្រសួងពាណិជ្ជកម្មរបស់គេនឹងត្រូវឆូតពណ៌ក្រហម និង ចារថាបាន បិទទ្វារ ។

**ប្រការ ២ :** ការស៊ើបអង្កេតបន្ថែមទៀតនឹងត្រូវធ្វើឡើងដោយ នាយកដ្ឋានប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម , នាយកដ្ឋានពាណិជ្ជកម្មក្រៅប្រទេស , នាយកដ្ឋាននីតិកម្ម ទាក់ទិនបំណុល និង ការទទួលខុសត្រូវផ្សេងៗនៃរោងចក្រដែលមានឈ្មោះខាងលើចំពោះតតីយជននៅកម្ពុជា ព្រមទាំងបំណុលរបស់គេចំពោះច្បាប់ និង បទបញ្ញត្តិកម្ពុជា ។

**ប្រការ ៣ :** នាយិកាខុទ្ទកាល័យ , អគ្គនាយកបច្ចេកទេស , ប្រធាននាយកដ្ឋានប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម , ប្រធាននាយកដ្ឋានពាណិជ្ជកម្មក្រៅប្រទេស , ប្រធាននាយកដ្ឋាននីតិកម្ម និង រោងចក្រដែលមានឈ្មោះក្នុងប្រការ ១ ត្រូវអនុវត្តតាមប្រកាសនេះអោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**ចម ប្រសិទ្ធ**

**<u>ចម្លងជូន</u> :**

- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី *ស ខេង*
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី *សោ ណាំហុង*
- ខុទ្ទកាល័យទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- ក្រសួងឧស្សាហកម្មរ៉ែ និង ថាមពល
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា
- ក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ
- ស្ថានរាជទូតកម្ពុជាប្រចាំទីក្រុងប៉ារីស
- ស្ថានរាជទូតកម្ពុជាប្រចាំទីក្រុងវ៉ាស៊ីនតោនឌីស៊ី
- ស្ថានទូតសហរដ្ឋអាមេរិកប្រចាំនៅកម្ពុជា
- គណៈប្រតិភូសហគមន៍អឺរ៉ុបប្រចាំទីក្រុងបាងកក
- សមាគមកាត់ដេរសំលៀកបំពាក់នៅកម្ពុជា
- ដូចប្រការ ៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ



Ministry of Commerce # 20 A & B Preah Norodom Boulevard, Phnom Penh 12205 ( Kingdom of Cambodia )
Minister's Mobile Phone (855-12) 821888 Facsimile: (855-23) 213288
URL : http://www.moc.gov.kh E-Mail : champrasidh@hotmail.com
Staff's Mobile Phones: (855-12) 933 323 / 881223 Facsimile: (855-23) 426396